# ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

## កម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន
## កម្មវិធីស្តារសេដ្ឋកិច្ចបៃតង (ACGF GRP)

ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០២០

ចំណាំ ៖ ឯកសារនេះគាំទ្រដោយតំណភ្ជាប់ឯកសារខាងក្រោម ៖

- តំណភ្ជាប់ឯកសារទី ១ ៖ “សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី” (២០០៩)
- តំណភ្ជាប់ឯកសារទី ២ ៖ “គំរូឯកសាររបស់ធនគារអភិវឌ្ឍន៍អាស៊ីសម្រាប់ការចាត់ចំណាត់ថ្នាក់ និងការតាមដាន”

# ពាក្យកាត់

| | |
|---|---|
| ACGF | កម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AIF | មូលនិធិហេដ្ឋារចនាសម្ព័ន្ធអាស៊ាន |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) |
| CAP | ផែនការសកម្មភាពកែតម្រូវ |
| EIA | ការវាយតម្លៃផលប៉ះពាល់បរិស្ថាន |
| EIB | ធនាគារវិនិយោគអឺរ៉ុប |
| EHS | បរិស្ថាន សុខភាព និងសុវត្ថិភាព |
| EMP | ផែនការគ្រប់គ្រងបរិស្ថាន |
| E&S/ES | បរិស្ថាន និងសង្គម |
| ESMF | ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម |
| FI | អន្តរការីហិរញ្ញវត្ថុ |
| GCF | មូលនិធិអាកាសធាតុបៃតង |
| GRM | យន្តការដោះស្រាយបណ្តឹងតវ៉ា |
| IEE | ការត្រួតពិនិត្យបរិស្ថានដំបូង |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| IP | ក្រុមជនជាតិដើមភាគតិច |
| IPP | ផែនការក្រុមជនជាតិដើមភាគតិច |
| IR | ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត |
| PAP | ក្រុមមនុស្សរងផលប៉ះពាល់ដោយសារគម្រោង |
| PIAL | តារាងសកម្មភាពវិនិយោគដែលត្រូវបានហាមឃាត់ |
| PSs | បទដ្ឋានអនុវត្តន៍ការងារ |
| REA | ការវាយតម្លៃបរិស្ថានរហ័ស |
| RP | ផែនការតាំងទីលំនៅជាថ្មី |
| SIA | ការវាយតម្លៃផលប៉ះពាល់សង្គម |
| SPS | សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពារ |
| TNA | ការវាយតម្លៃតម្រូវការបណ្តុះបណ្តាល |

## មាតិកា

១.44

ក.**Error! Bookmark not defined.**5

ខ.77

គ.1010

២.**Error! Bookmark not defined.**13

ក.**Error! Bookmark not defined.**13

ខ.**Error! Bookmark not defined.**15

គ.**Error! Bookmark not defined.**22

ឃ.**Error! Bookmark not defined.**25

ង.**Error! Bookmark not defined.**28

ច.2929

ឆ.2929

ជ.3030

ឧបសម្ព័ន្ធ ១ ៖ គំរូឯកសារ និងតារាងផ្ទៀងផ្ទាត់របស់ធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់ការចាត់ចំណាត់ថ្នាក់ការអង្កេតលម្អិត និងការតាមដាន 32

# ១.សេចក្តីផ្តើម

1. ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ក្នុងកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន (ACGF GRP) ត្រូវបានអភិវឌ្ឍឡើងក្នុងគោលបំណងកាត់បន្ថយជាអតិបរមានូវហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គមដោយសារគម្រោងទាំងអស់ដែលស្ថិតក្រោមកម្មវិធីនេះ និងបន្ធូរបន្ថយហានិភ័យ និងផលប៉ះពាល់ទាំងនោះមកត្រឹមកម្រិតដែលអាចទទួលយកបាន។ ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមកំណត់ពីគោលការណ៍ វិធាន នីតិវិធី និងគោលការណ៍ណែនាំសម្រាប់ការអង្កេតលម្អិតពីបរិស្ថាន និងសង្គមនៃគម្រោង ដែលអាចពាក់ព័ន្ធនឹងកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន។ គម្រោងទាំងអស់នេះត្រូវអនុលោមតាមគោលនយោបាយ និងលក្ខខណ្ឌតម្រូវសម្រាប់ការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូចមានចែងក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (SPS)[1]។ ប្រសិនបើគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវបានធ្វើវិសោធនកម្មក្នុងពេលអនុវត្តកម្មវិធីនេះ ត្រូវគោរពតាមលក្ខខណ្ឌតម្រូវសម្រាប់ការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅពេលរៀបចំគម្រោងនេះ។

2. សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានគោលបំណងជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិករបស់ខ្លួនក្នុងការដោះស្រាយហានិភ័យបរិស្ថាន និងសង្គមក្នុងគម្រោងអភិវឌ្ឍន៍ និងកាត់បន្ថយ និងប្រសិនបើមិនអាចបញ្ចៀសបាន បន្ធូរបន្ថយផលប៉ះពាល់អវិជ្ជមានរបស់គម្រោងលើមនុស្ស និងបរិស្ថាន។ ក្រោមការអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី កាលពីខែ កក្កដា ឆ្នាំ ២០០៩ សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីផ្អែកលើគោលនយោបាយការពារ ចំនួន ៣ ដូចជា ការការពារបរិស្ថាន ការការពារការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងការការពារក្រុមជនជាតិដើមភាគតិច និងដាក់បញ្ចូលគោលនយោបាយទាំងនេះក្នុងក្របខណ្ឌគោលនយោបាយរួមមួយដែលបង្កើនប្រសិទ្ធភាព និងភាពពាក់ព័ន្ធ។ ក្នុងការអនុវត្តសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពារនេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានសហការជាមួយអ្នកខ្ចីដើម្បីអនុវត្តគោលការណ៍គោលនយោបាយ និងលក្ខខណ្ឌតម្រូវក្នុងការវាយតម្លៃ និងការត្រួតពិនិត្យគម្រោង និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព។ ក្រៅពីនេះ សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពារនឹងផ្តល់វេទិកាសម្រាប់ជម្រុញការចូលរួមរបស់ក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងប្លង់រចនា និងការអនុវត្តគម្រោង។

3. សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ពាក់ព័ន្ធនឹងដំណើរការដែលត្រូវបានរៀបចំឡើង ដូចជា ការត្រួតពិនិត្យផលប៉ះពាល់ ការវាយតម្លៃ ការរៀបចំផែនការ និងការបន្ធូរបន្ថយផលប៉ះពាល់ ដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមានដោយសារគម្រោងក្នុងវដ្តគម្រោង។ គោលនយោបាយការពារតម្រូវ

[1] ADB. 2009. សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពារ ទីក្រុងម៉ានីល

ឱ្យមានការ (១) កំណត់រក និងវាយតម្លៃផលប៉ះពាល់តាំងពីដំបូងក្នុងវដ្តគម្រោង (២) រៀបចំ និងអនុវត្តផែនការបញ្ចៀស កាត់បន្ថយ បន្ធូរបន្ថយ ឬប៉ះប៉ូវសងនូវផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន និង (៣) ជូនដំណឹង និងពិគ្រោះយោបល់ជាមួយក្រុមមនុស្សរងផលប៉ះពាល់ក្នុងពេលរៀបចំ និងអនុវត្តគម្រោង។

## ក.សាវតា ស្តីពីកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន

4. កម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន (ACGF GRP) គឺជាវេទិកាថ្មីមួយដែលមានឧបករណ៍ចម្រុះ និងបង្កើតឡើងតាមប្រទេសនីមួយៗ ដើម្បីពង្រីកការវិនិយោគលើការបំភាយឧស្ម័នតិច ដែលជាផ្នែកមួយនៃការជម្រុញសេដ្ឋកិច្ចក្នុងវិបត្តិកូវីដ ១៩។ តាមរយៈការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធបៃតងដែលបំភាយឧស្ម័នតិច[2] ដែលផ្តោតជាពិសេសលើការស្តារសេដ្ឋកិច្ចក្រោយវិបត្តិកូវីដ ១៩ កម្មវិធីនេះនឹងជួយដល់បណ្តាប្រទេសទាំងឡាយក្នុងការបញ្ចៀសការកើតឡើងវិញនូវការបំភាយឧស្ម័ន និងការរេចរិលបរិស្ថាន ក៏ដូចជាជម្រុញកំណើនសេដ្ឋកិច្ចតាមរយៈការបង្កើតការងារបៃតង។

5. កម្មវិធីនេះនឹងប្រើប្រាស់ហិរញ្ញប្បទានរបស់មូលដ្ឋានអាកាសធាតុបៃតង ដើម្បីទាញប្រយោជន៍ពីធនធានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិហេដ្ឋារចនាសម្ព័ន្ធអាស៊ាន ដៃគូសហការផ្តល់ហិរញ្ញប្បទានផ្សេងទៀត និងរដ្ឋាភិបាល។ ការវិនិយោគរបស់កម្មវិធីនេះនឹងលើកឡើងពីសកម្មភាពជាក់ស្តែងសម្រាប់ការស្តារសេដ្ឋកិច្ចបៃតងតាមរយៈការដាក់បញ្ចូលបទដ្ឋានអន្តរជាតិសម្រាប់ផលប៉ះពាល់អាកាសធាតុ ដែលត្រួសត្រាយផ្លូវសម្រាប់ការរៀបចំបញ្ជីគម្រោងដែលបញ្ចេញកាបូនតិចក្នុងរយៈពេលវែង ដោយបង្កើតជាដ្ឋានសម្រាប់ការផ្លាស់ប្តូរគំរូដ៏ធំទូលាយនៅអាស៊ីអាគ្នេយ៍។

6. កម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន មានទម្រង់ជាមូលនិធិវិលជុំដែលបង្វិលការប្រើប្រាស់មូលនិធអាកាសធាតុបៃតងក្នុងការវិនិយោគចំនួន ២។ កម្មវិធីនេះនឹងប្រើប្រាស់ហិរញ្ញប្បទានរបស់មូលនិធិអាកាសធាតុបៃតងចំនួន ៣៥០ លានដុល្លារ (កម្ចី ៣២០ លានដុល្លារ និងឥណទានសម្បទានសម្រាប់ជំនួយបច្ចេកទេសចំនួន ៣០ លានដុល្លារ) ដើម្បីបំពេញបន្ថែមដល់ធនធានរបស់កម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន ក្នុងការគាំទ្រគម្រោងដែលបង្កផលប៉ះពាល់ខ្ពស់លើអាកាសធាតុ និងគម្រោងហេដ្ឋារចនាសម្ព័ន្ធបៃតងក្រោយវិបត្តិកូវីដ ១៩ ដែលបង្កើតការងារ និងទ្រទ្រង់កំណើនសេដ្ឋកិច្ច។

[2] សម្រាប់គោលបំណងក្នុងកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន ហេដ្ឋារចនាសម្ព័ន្ធបៃតងសំដៅលើហេដ្ឋារចនាសម្ព័ន្ធដែលផ្តល់អត្ថប្រយោជន៍គួរឱ្យកត់សម្គាល់ដល់អាកាសធាតុ ដែលបានរួមចំណែកដល់គោលបំណងបរិស្ថានផ្សេងទៀត ដូចជា ការកាត់បន្ថយការបំពុល ការបង្កើនប្រសិទ្ធផលនៃការប្រើប្រាស់ធនធាន និងការគ្រប់គ្រងមូលធនធម្មជាតិ។

7. កម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន មានសមាសភាគ ៣ ដូចខាងក្រោម ៖

## សមាសភាគទី ១ ៖ ការកាត់បន្ថយហានិភ័យមូលនិធិសម្រាប់គម្រោងបំភាយឧស្ម័នតិច

8. កម្ចីរបស់មូលនិធិអាកាសធាតុបៃតង នឹងបំពេញបន្ថែមឱ្យហិរញ្ញប្បទានរបស់កម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន និងធនាគារអភិវឌ្ឍន៍អាស៊ី និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត (ទៅតាមភាពសមស្រប) ដើម្បីកាត់បន្ថយហានិភ័យមូលនិធិ សំដៅបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទានពីធនាគារនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធបៃតងដែលបំភាយឧស្ម័នតិច។ កម្មវិធីនេះនឹងផ្តល់ដល់កម្ចីដល់គម្រោងបំភាយឧស្ម័នតិចតាមប្រទេសចំនួន ២៣ ចាប់ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០៥០ ដែលគម្រោងនីមួយៗត្រូវបំពេញលក្ខណៈវិនិច្ឆ័យជាក់លាក់ដែលពាក់ព័ន្ធនឹងផលប៉ះពាល់អាកាសធាតុ លទ្ធភាពទទួលបានហិរញ្ញប្បទានពីធនាគារការកៀរគរវិស័យឯកជន និងការបង្កើតការងារបៃតង។

9. គម្រោងក្រោមកម្មវិធីនេះ នឹងត្រូវបានជ្រើសរើសចេញពីបញ្ជីគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅតាមប្រទេសនីមួយៗ ដែលត្រូវឆ្លងកាត់ការត្រួតពិនិត្យធៀបនឹងលក្ខណៈវិនិច្ឆ័យលក្ខណៈសម្បត្តិនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន និងការពិគ្រោះយោបល់ជាមួយរដ្ឋាភិបាល និងវិស័យ និងក្រុមថ្នាក់ប្រទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

## សមាសភាគទី ២ ៖ ការអភិវឌ្ឍគំរូ និងរចនាសម្ព័ន្ធហិរញ្ញវត្ថុអាកាសធាតុបែបនវានុវត្តន៍

10. ហិរញ្ញប្បទានរបស់មូលនិធិអាកាសធាតុបៃតង (ឥណទានសម្បទានសម្រាប់ជំនួយបច្ចេកទេស) នឹងគាំទ្រ និងពង្រីកឧបករណ៍ និងរចនាសម្ព័ន្ធហិរញ្ញប្បទានថ្មីៗដោយផ្តោតសំខាន់លើ ក) ប័ណ្ណបំណុលបៃតង និងមាននិរន្តរភាព ខ) គំរូ PPP បែបកូនកាត់សម្រាប់ថាមពលកកើតឡើងវិញ និងទីក្រុងដែលមាននិរន្តរភាព និង គ) យន្តការថ្មីសម្រាប់ការផ្តល់ហិរញ្ញប្បទានដល់ការស្តារសេដ្ឋកិច្ចបៃតង។

## សមាសភាគទី ៣ ៖ ការគាំទ្រដល់គោលនយោបាយ ចំណេះដឹង និងការកសាងសមត្ថភាព

11. ហិរញ្ញប្បទានរបស់មូលនិធិអាកាសធាតុបៃតង (ឥណទានសម្បទានសម្រាប់ជំនួយបច្ចេកទេស) នឹងត្រូវបានប្រើប្រាស់សម្រាប់ជួយកសាងការយល់ដឹង ចំណេះដឹង និងជម្រុញកិច្ចសន្ទនាគោលនយោបាយស្តីពីហិរញ្ញវត្ថុបៃតងក្នុងតំបន់អាស៊ាន ដោយផ្តោតសំខាន់លើការគាំទ្រដល់ការបង្កើនប្រតិបត្តិការ និងការកសាងសមត្ថភាពសំដៅធ្វើយ៉ាងណាឱ្យការកំណត់រក ការរៀបចំរចនាសម្ព័ន្ធ និងការអនុវត្តឱកាសគម្រោងដែលបញ្ចេញកាបូនតិចមានភាពប្រសើរឡើង។ ក្រៅពីការអភិវឌ្ឍយុទ្ធសាស្ត្រហិរញ្ញវត្ថុបៃតង និងការរៀបចំព្រឹត្តិការណ៍កសាងចំណេះដឹង នឹងមានការបណ្តុះបណ្តាលស្តីពីហិរញ្ញវត្ថុថ្មីៗក្នុងកម្មវិធី "ឈានមុខទាំង ៦" នៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន។

12. ការកសាងសមត្ថភាពក្រោមសមាសភាគនេះ នឹងគាំទ្រដល់ការអនុវត្តគោលនយោបាយការពារប្រកបដោយប្រសិទ្ធភាពតាមរយៈវគ្គបណ្តុះបណ្តាលជាក់លាក់សម្រាប់បុគ្គលិករបស់ស្ថាប័នគាំទ្រគម្រោង ដើម្បីកសាងចំណេះដឹងស្តីពីលក្ខខណ្ឌតម្រូវសម្រាប់ការពារ (បរិស្ថាន និងសង្គម) របស់ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិអាកាសធាតុបៃតង និងពង្រឹងជំនាញ សមត្ថភាព និងចំណេះដឹងស្តីពីការតាមដាន និងការអនុវត្តផែនការគ្រប់គ្រងដែលពាក់ព័ន្ធនឹងបរិស្ថាន ការតាំងទីលំនៅជាថ្មី និងក្រុមជនជាតិដើមភាគតិច។

## ការរៀបចំការអនុវត្ត

13. កម្មវិធីនេះនឹងត្រូវគ្រប់គ្រងដោយធនាគារអភិវឌ្ឍន៍អាស៊ីក្នុងនាមជាស្ថាប័ន ដែលទទួលស្គាល់ដោយមូលនិធិអាកាសធាតុបៃតង និងជាស្ថាប័នប្រតិបត្តិ (ដែលកំណត់ដោយមូលនិធិអាកាសធាតុបៃតង)។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងទទួលខុសត្រូវលើការផ្តល់កម្ចី និងមូលនិធិជំនួយបច្ចេកទេសពីមូលនិធិអាកាសធាតុបៃតងក្រោមកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន។ មូលនិធិសម្រាប់កម្មវិធីស្តារសេដ្ឋកិច្ចបៃតងនឹងត្រូវបានផ្តល់ជូនទន្ទឹមគ្នានឹងមូលនិធិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់គម្រោងដែលត្រូវបានដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រភាពជាដៃគូថ្នាក់ប្រទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងផែនការអាជីវកម្មប្រតិបត្តិការថ្នាក់ប្រទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងគ្រប់គ្រង និងត្រួតពិនិត្យក្រុមរៀបចំរចនាសម្ព័ន្ធគម្រោងរបស់កម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន ដែលមានសមាសភាគអ្នកជំនាញដែលធ្វើការពេញម៉ោង និងបណ្តោះអាសន្ន ដើម្បីដំណើរការកម្មវិធីនេះ។

14. កម្មវិធីនេះនឹងផ្សារភ្ជាប់ជាមួយកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន ជាកម្មវិធីមួយដែលស្ថិតក្រោមមូលនិធិហេដ្ឋារចនាសម្ព័ន្ធអាស៊ាន ដែលគ្រប់គ្រងដោយរដ្ឋសមាជិកអាស៊ាន និងធនាគារអភិវឌ្ឍន៍អាស៊ី។ កម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន ត្រូវបានអនុវត្តដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាននៅថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៩ នៅឈៀងរ៉ៃ ប្រទេសថៃ ក្នុងផ្នែកមួយនៃកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន។

## ខ.ការចាត់ចំណាត់ថ្នាក់ហានិភ័យ ក្នុងកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន

### ហានិភ័យបរិស្ថាន និងសង្គម ដែលរំពឹងថានឹងបណ្តាលមកពីអនុគម្រោងក្នុងកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន

15. វិស័យអាទិភាពសម្រាប់កម្មវិធីនេះរួមមាន ៖

- ប្រព័ន្ធថាមពលកកើតឡើងវិញ ៖ ប្រសិទ្ធផលថាមពលក្នុងវិស័យឧស្សាហកម្ម និងសំណង់ ប្រសិទ្ធផលថាមពលក្នុងវិស័យដឹកជញ្ជូន ការស្តុកទុក និងការបញ្ជូនថាមពល ដើម្បីគាំទ្រដល់ការបង្កើនការដាក់បញ្ចូលថាមពលកកើតឡើងវិញក្នុងបណ្តាញផ្គត់ផ្គង់ថាមពល។

- **ប្រព័ន្ធដឹកជញ្ជូនក្នុងក្រុងដែលបញ្ចេញកាបូនតិច** (ផ្លូវរថភ្លើងក្នុងទីក្រុង ផ្លូវរថភ្លើងក្រោមដី រថយន្តក្រុងល្បឿនលឿន) ការអភិវឌ្ឍបណ្តាញផ្លូវដែកក្នុងទីក្រុងដែលប្តូររបៀបប្រើប្រាស់ថាមពល ប្រព័ន្ធដឹកជញ្ជូនសាធារណៈ ប្រព័ន្ធដឹកជញ្ជូនយ៉ាងសកម្ម (ដូចជា ការជិះកង់ ថ្មើរជើង) ហេដ្ឋារចនាសម្ព័ន្ធយានយន្តដើរដោយថាមពលអគ្គិសនី។
- **គម្រោងធនធានធម្មជាតិ និងកសិកម្មដែលមាននិរន្តរភាព** (រួមបញ្ចូលសមាសធាតុហេដ្ឋារចនាសម្ព័ន្ធ) ដូចជា ការដាំដើមឈើឡើងវិញ និងការគ្រប់គ្រងព្រៃកោងកាងប្រកបដោយនិរន្តរភាព ការអភិវឌ្ឍសង្វាក់តម្លៃដែលបញ្ចេញកាបូនតិច ដលផលដែលមាននិរន្តរភាព និងសុខភាពសមុទ្រ។
- **គម្រោងពហុវិស័យបៃតងក្នុងទីក្រុង** ដូចជា ការផ្គត់ផ្គង់ទឹកដែលមានប្រសិទ្ធផលថាមពល និងធន់នឹងអាកាសធាតុ និងប្រព្រឹត្តកម្មទឹកស្អុយ អនាម័យ ប្រព័ន្ធគ្រប់គ្រងសំរាម ការគ្រប់គ្រង និងកាត់បន្ថយការបំពុល។

16. ខណៈដែលហានិភ័យបរិស្ថាន និងសង្គមប្រែប្រួលទៅតាមប្រទេស និងបរិបទ ជាទូទៅ គម្រោងក្នុងវិស័យអាទិភាពក្រោមគម្រោងនេះ អាចពាក់ព័ន្ធនឹងហានិភ័យជាច្រើនដែលត្រូវកាត់បន្ថយ និងបន្ធូរបន្ថយផលប៉ះពាល់ជាចាំបាច់តាមរយៈក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមក្នុងកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន។ សេចក្តីសង្ខេបស្តីពីហានិភ័យទាំងនេះមានបង្ហាញក្នុងតារាង ១។

### តារាង ១ ៖ ការប៉ាន់ស្មានហានិភ័យផ្នែកបរិស្ថាន និងសង្គមសម្រាប់គម្រោងក្នុងវិស័យអាទិភាព

| វិស័យ អាទិភាព | ឧទាហរណ៍ហានិភ័យដែលត្រូវបានប៉ាន់ស្មានក្នុងគម្រោង | | | ប្រភេទ ហានិភ័យ របស់ធនាគារ អភិវឌ្ឍន៍អាស៊ី * |
|---|---|---|---|---|
| | Environment | ហានិភ័យសង្គម | | |
| | | ការតាំងទីលំនៅជាថ្មី ដោយមិនស្ម័គ្រចិត្ត (IR) | ជនជាតិដើម ភាគតិច (IP) | |
| ប្រព័ន្ធថាមពលកកើតឡើងវិញ | លទ្ធកម្មដី (ជាពិសេសសម្រាប់ទីតាំងគម្រោង តំបន់បញ្ជូនបន្ត និងតំបន់ស្តុកទុកថាមពល)<br>សំណល់គ្រោះថ្នាក់ (គ្រឿងផ្ទុះ និងទឹកស្អុយ) និងការបំភាយឧស្ម័ន សំឡេងរំខានក្នុងពេលសាងសង់<br>ការបំភាយឧស្ម័នផ្ទះកញ្ចក់<br>ការគ្រប់គ្រងវត្ថុធាតុដែលខូចគុណភាព និងកកើតឡើងវិញ<br>សំឡេងរំខាន និងផលប៉ះពាល់នៃម្លប់<br>បញ្ហាពាក់ព័ន្ធនឹងការងារ<br>ចរាចរណ៍ សុវត្ថិភាព និងសន្តិសុខក្នុងពេលសាងសង់<br>ការគ្រប់គ្រងទឹកជំនន់ និងព្យុះភ្លៀងក្នុងមូលដ្ឋាន<br>កង្វះហេដ្ឋារចនាសម្ព័ន្ធគាំទ្រ | លទ្ធកម្មដីអាចធ្វើឱ្យមានការផ្លាស់ទីលំនៅរូបវន្ត និងការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ច។ អាចមានការតាំងទីលំនៅជាថ្មីជាបណ្តោះអាសន្ន។<br>ការទទួលយកដោយតំបន់ជិតខាង និងការទទួលយកដោយអាជីវកម្ម (ការជំទាស់របស់សាធារណៈជន)<br>ភាពអាចលៃលកប្រព័ន្ធថាមពលថ្មី<br>ផលប៉ះពាល់នៃលំហូរចូលកម្មករ/កម្លាំងពលកម្ម<br>ការទទួលយកផ្នែកទិដ្ឋភាព | អាចមានហានិភ័យប្រសិនបើមានវត្តមានជនជាតិដើមភាគតិច (ឧ. ទីក្រុងម៉ានីល មានតំបន់ជាច្រើនដែលប្រមូលផ្តុំដោយជនជាតិដើមភាគតិច និងបរិពន្ធភូមិដូនតា)<br>អនុវត្តដំណើរការជម្រុញការគាំទ្រក្នុងសហគមន៍។ | ក, ខ និង គ |

| | | | | |
|---|---|---|---|---|
| មធ្យោបាយដឹកជញ្ជូនក្នុងទីក្រុងដែលបញ្ចេញកាបូនតិច | លទ្ធកម្មដី<br>សំណល់គ្រោះថ្នាក់ (គ្រឿងផ្ទុះ និងទឹកស្អុយ) ការបំភាយឧស្ម័ន សំឡេងរំខាន ធូលី និងការបំពុល<br>ការខូចគុណភាព<br>ហានិភ័យដោយសារការផ្លាស់ប្តូរផ្លូវជាបណ្តោះអាសន្ន (យានយន្តចរាចរណ៍) និងយានយន្តដឹកជញ្ជូនសម្ភារសំណង់<br>ការងារ សុវត្ថិភាព និងសុខភាព (ក្នុងពេលសាងសង់)<br>កង្វះហេដ្ឋារចនាសម្ព័ន្ធគាំទ្រ | ការតាំងទីលំនៅជាថ្មី (បណ្តោះអាសន្ន និងអចិន្ត្រៃយ៍)<br>មធ្យោបាយចិញ្ចឹមជីវិត<br>ការផ្លាស់ប្តូរផ្លូវជាបណ្តោះអាសន្ន<br>ភាពអាចលៃលកមធ្យោបាយដឹកជញ្ជូនថ្មី (សម្រាប់ជនងាយរងគ្រោះ និងយុវជន)<br>ការគ្រប់គ្រងទឹកជំនន់ និងព្យុះភ្លៀងក្នុងមូលដ្ឋាន ដែលប៉ះពាល់ដល់មធ្យោបាយចិញ្ចឹមជីវិត<br>ផលប៉ះពាល់នៃលំហូរចូលកម្មករ/កម្លាំងពលកម្ម | ក្រុមជនជាតិដើមភាគតិចអាចរងផលប៉ះពាល់ក្នុងទីក្រុងមួយចំនួន (ឧ. ប្រទេសហ្វីលីពីន មីយ៉ាន់ម៉ា វៀតណាម)<br>អនុវត្តដំណើរការជម្រុញការគាំទ្រក្នុងសហគមន៍។ | ក, ខ និង គ |
| ធនធានធម្មជាតិ និងកសិកម្មដែលមាននិរន្តរភាព | លទ្ធកម្មដី<br>ជីវៈចម្រុះ<br>អេកូឡូស៊ីវារីវប្បកម្ម<br>ការបំពុលតំបន់ឆ្នេរ<br>ការធ្វើអាជីវកម្មធនធានដោយខុសច្បាប់ | ការផ្លាស់ប្តូរការប្រើប្រាស់ដី និងមធ្យោបាយចិញ្ចឹមជីវិត<br>អាចមានការតាំងទីលំនៅជាថ្មីប្រសិនបើមានការគ្រប់គ្រងព្រៃឈើ<br>ការផ្លាស់ប្តូររបរចិញ្ចឹមជីវិត (ដោយសារលទ្ធភាពអាស្រ័យផលពីដំណាំ និងជលផលតំបន់ឆ្នេរ)<br>ក្រុមងាយរងគ្រោះ | ក្រុមជនជាតិដើមភាគតិចតំបន់ដូនតា<br>អនុវត្តដំណើរការជម្រុញការគាំទ្រក្នុងសហគមន៍។ | ក (ប្រហែលជាសម្រាប់បរិស្ថាន) ខ និង គ |
| គម្រោងពហុវិស័យបៃតងក្នុងទីក្រុង | លទ្ធកម្មដី (ដូចជា កសិកម្ម ឬវាលស្មៅ/តំបន់ព្រៃ)<br>សំណល់គ្រោះថ្នាក់ និងសំណល់ពុល<br>ក្លិនខ្យល់ និងសំរាម<br>គុណភាពទឹក និងដែនជំរក/អេកូឡូស៊ី<br>ការបំភាយឧស្ម័នផ្ទះកញ្ចក់<br>ការគ្រប់គ្រងការបំពុល និងកាកសំណល់<br>ការគ្រប់គ្រងចរាចរណ៍យានយន្ត (ដឹកជញ្ជូនសំរាម និងសម្ភារៈសាងសង់)<br>ការងារ សុវត្ថិភាព និងសុខភាព | ការប្រើប្រាស់ និងលទ្ធកម្មដី<br>ការតាំងទីលំនៅជាថ្មី<br>សុវត្ថិភាពក្នុងពេលសាងសង់<br>សុខភាព និងធាតុចេញ/សំណល់<br>ការផ្លាស់ប្តូរលទ្ធភាពប្រើប្រាស់ធនធានទឹកជាបណ្តោះអាសន្ន<br>ផលប៉ះពាល់នៃលំហូរចូលកម្មករ/កម្លាំងពលកម្ម<br>ការទទួលយកដោយតំបន់ជិតខាង និងការទទួលយកដោយអាជីវកម្ម (ការជំទាស់របស់សាធារណៈជន)<br>ការទទួលយកផ្នែកទិដ្ឋភាព | ក្រុមជនជាតិដើមភាគតិចអាចរងផលប៉ះពាល់ក្នុងទីក្រុងមួយចំនួន។<br>អនុវត្តដំណើរការជម្រុញការគាំទ្រក្នុងសហគមន៍។ | ក, ខ និង គ |

*សូមមើលការត្រួតពិនិត្យ និងចាត់ចំណាត់ថ្នាក់ហានិភ័យសម្រាប់ការតាំងទីលំនៅជាថ្មីរវាងគម្រោងប្រភេទ ក និងគម្រោងប្រភេទ ខ ក្នុងតារាង ២ អនុលោមតាមសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០០៩)

## ការចាត់ចំណាត់ថ្នាក់ហានិភ័យក្នុងក្របខណ្ឌរបស់មូលនិធិអាកាសធាតុបៃតង

17. កម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន ត្រូវបានចាត់ជាប្រភេទ I-1 ក្រោមការចាត់ចំណាត់ថ្នាក់ហានិភ័យបរិស្ថាន និងសង្គមរបស់មូលនិធិអាកាសធាតុបៃតង។ ក្នុងកម្មវិធីនេះ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងផ្តល់កម្ចី និងជំនួយបច្ចេកទេសពីមូលនិធិរបស់មូលនិធិអាកាសធាតុបៃតង ទន្ទឹមគ្នានឹងមូលនិធិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ កម្មវិធីនេះផ្តោតលើហេដ្ឋារចនាសម្ព័ន្ធដែលបំភាយឧស្ម័នតិច និងមានរយៈពេលរហូតដល់ ៣០ ឆ្នាំ។ ដូច្នេះ អនុគម្រោងដែលត្រូវបានចាត់ចំណាត់ថ្នាក់ក្រោមប្រភេទនៃការការពារទាំងអស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ក, ខ និង គ) អាចទទួលបានហិរញ្ញប្បទានក្នុងពេលអនុវត្តកម្មវិធី។ ប្រភេទអនុគម្រោងនាពេលអនាគតក្នុងកម្មវិធីនេះ អាចរួមបញ្ចូលសកម្មភាពដែល “អាចបង្កហានិភ័យ និងផលប៉ះពាល់អវិជ្ជមានគួរឱ្យកត់សម្គាល់លើបរិស្ថាន និងសង្គម ដែលហានិភ័យ និងផលប៉ះពាល់នីមួយៗ ឬរួមបញ្ចូលគ្នាមានលក្ខណៈចម្រុះ មិនអាចកែប្រែបាន ឬមិនធ្លាប់មានពីមុនមក” ទៅតាមការកំណត់ដោយមូលនិធិអាកាសធាតុបៃតង។

## គ.គោលការណ៍ជាមូលដ្ឋាននៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ក្នុងកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន

18. ដើម្បីកំណត់រក និងដោះស្រាយដោយប្រសិទ្ធភាពនូវផលប៉ះពាល់ដែលអាចកើតឡើងដោយសារគម្រោងដែលទទួលបានជំនួយពីមូលនិធិអាកាសធាតុបៃតង (តាមរយៈកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន) ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមត្រូវបានបង្កើតឡើងដោយអនុលោមតាមសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ គម្រោងនីមួយៗនឹងឆ្លងកាត់ការពិនិត្យរកគុណសម្បត្តិផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ មុននឹងអនុលោមតាមការត្រួតពិនិត្យការការពារ ការពិនិត្យឡើងវិញ និងការវាយតម្លៃ ដោយផ្អែកតាមក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមនេះ។ ប្រព័ន្ធនេះនឹងអនុវត្តចំពោះគម្រោងទាំងឡាយណាដែលប្រើប្រាស់ជំនួយរបស់មូលនិធិអាកាសធាតុបៃតង (តាមរយៈកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន)។

19. ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមបង្ហាញពីតួនាទី ការទទួលខុសត្រូវ និងនីតិវិធីដើម្បីបញ្ចៀស កាត់បន្ថយ និងបន្ធូរបន្ថយផលប៉ះពាល់ និងហានិភ័យផ្ទាល់ ប្រយោល ត្រួតស៊ីគ្នា និងជាការបង្ក ដូចខាងក្រោម ៖

ក) ផលប៉ះពាល់ និង/ឬហានិភ័យអវិជ្ជមានលើបរិស្ថាន

ខ) ផលប៉ះពាល់ និងហានិភ័យអវិជ្ជមាននៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និង

គ) ផលប៉ះពាល់អវិជ្ជមានលើក្រុមជនជាតិភាគតិច[3] និងសហគមន៍របស់ពួកគេ ដែលអាចបណ្តាលមកពីការអនុវត្តគម្រោង និងអនុគម្រោង។

20. គម្រោងទាំងអស់ ដែលស្ថិតក្រោមកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន នឹងត្រូវបានផ្តល់សហហិរញ្ញប្បទាន និងដំណើរការដោយធនាគារអភិវឌ្ឍន៍អាស៊ី និងត្រូវអនុលោមតាមគោលបំណង និងលក្ខខណ្ឌតម្រូវក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ផ្អែកតាមលក្ខខណ្ឌតម្រូវក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារអភិវឌ្ឍន៍អាស៊ីនឹងអនុវត្តគោលការណ៍ណែនាំស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាព (EHS) របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិដើម្បីធានាការរៀបចំវិធានការគ្រប់គ្រាន់ក្នុងគម្រោង[4]។

21. យោងតាមសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារអភិវឌ្ឍន៍អាស៊ីនឹងមិនផ្តល់ហិរញ្ញប្បទានដល់គម្រោង ដែលមិនគោរពតាមសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ខ្លួនឡើយ ហើយក៏មិនផ្តល់ហិរញ្ញប្បទានដល់គម្រោងដែលមិនគោរពតាមច្បាប់ និងបទបញ្ញាពាក់ព័ន្ធស្តីពីសង្គម និងបរិស្ថានរបស់ប្រទេសម្ចាស់ផ្ទះឡើយ រួមទាំងច្បាប់ដែលតម្រូវឱ្យប្រទេសម្ចាស់ផ្ទះបំពេញកាតព្វកិច្ចដែលមានចែងក្នុងច្បាប់អន្តរជាតិដែរ។ លើសពីនេះ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងមិនផ្តល់ហិរញ្ញប្បទានចំពោះសកម្មភាពដែលមានក្នុងបញ្ជីសកម្មភាពវិនិយោគដែលត្រូវបានហាមឃាត់ឡើយ (សេចក្តីបន្ថែម ៥ នៃសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពារ)។ ប្រភេទទាំងអស់នៃការការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ក, ខ និង គ) សម្រាប់គម្រោងពាក់ព័ន្ធ នឹងត្រូវបានយកមកពិចារណា ហើយលក្ខខណ្ឌតម្រូវសម្រាប់ការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីនឹងត្រូវបានយកមកអនុវត្តដើម្បីបញ្ចៀស កាត់បន្ថយ បន្ធូរបន្ថយ និងប៉ះប៉ូវសងនូវហានិភ័យ និងផលប៉ះពាល់ដែលអាចកើតឡើង។

22. ក្នុងការអនុវត្តក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម និងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារអភិវឌ្ឍន៍អាស៊ីនឹងសហការជាមួយរដ្ឋាភិបាលរបស់អ្នកខ្ចីដើម្បីធ្វើយ៉ាងណាឱ្យគម្រោងដែលមានសក្តានុពលទាំងអស់ ក្នុងកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន៖

១. ត្រូវបានត្រួតពិនិត្យ ចាត់ចំណាត់ថ្នាក់ និងវាយតម្លៃសមស្របលើផលប៉ះពាល់ និងហានិភ័យបរិស្ថាន និងសង្គម ធៀបនឹងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងមានការកំណត់រកសកម្មភាពដែលបានសម្រេចយកដើម្បីបំបាត់គម្លាត

[3] គួរកត់សម្គាល់ថា ប្រទេសនានាប្រើប្រាស់ពាក្យបច្ចេកទេសផ្សេងៗជាច្រើនដើម្បីសំដៅលើក្រុមជនជាតិដើមភាគតិច ដូចជា ក្រុមជនអន្តោគ្រាមដើមភាគតិច សហគមន៍វប្បធម៌ដើមភាគតិច អ្នកស្រុកដើម កុលសម្ព័ន្ធភ្នំ ជនជាតិភាគតិច ក្រុមកុលសម្ព័ន្ធងាយរងគ្រោះ ក្រុមកុលសម្ព័ន្ធ។

[4] សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ គោលការណ៍ណែនាំស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាព www.ifc.org/ehsguidelines

២. ត្រូវបានពិនិត្យឡើងវិញ និងវាយតម្លៃធៀបនឹងគោលនយោបាយ ច្បាប់ បទប្បញ្ញត្តិ និងបទដ្ឋានជាតិស្តីពីបរិស្ថាន សុខភាព សុវត្ថិភាព ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងលទ្ធកម្មដី ក្រុមជនជាតិដើមភាគតិច និងធនធានវប្បធម៌រូបវន្ត និងការពិគ្រោះយោបល់សាធារណៈពោរពេញដោយអត្ថន័យ

៣. ដោះស្រាយបញ្ហាយេនឌ័រ និងការអភិវឌ្ឍ ដូចជា តាមរយៈការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ ជាមួយអ្នកពាក់ព័ន្ធ (រួមទាំងស្ត្រី និងកែសម្រួលទៅតាមតម្រូវការរបស់ក្រុមទន់ខ្សោយ និងក្រុមងាយរងគ្រោះ)

៤. បង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ា (GRM) ដើម្បីទទួល និងសម្រួលដល់ការដោះស្រាយក្តីកង្វល់ និងបណ្តឹងតវ៉ារបស់ក្រុមមនុស្សរងផលប៉ះពាល់ ដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយការពារបរិស្ថាន និងសង្គមរបស់គម្រោង

៥. ត្រូវបានដាក់បញ្ចូលក្នុងកិច្ចសន្យាជាមួយអ្នកទទួលការសាងសង់ អ្នកទទួលការបន្ត និងអ្នកផ្តល់ទំនិញ និងសេវាផ្សេងទៀតក្នុងការជួលកម្មករក្នុងមូលដ្ឋាន និងជានាការអនុលោមតាមលក្ខខណ្ឌតម្រូវសម្រាប់ការពារសង្គមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងបទដ្ឋានការងារអន្តរជាតិសំខាន់ៗ ដូចមានកំណត់ក្នុងសៀវភៅណែនាំស្តីពីបទដ្ឋានការងារសំខាន់ៗរបស់ធនាគារអភិវឌ្ឍន៍អាស៊ី[5]។

23. បទដ្ឋានបណ្តោះអាសន្នស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាពដែលកំពុងអនុវត្តដោយមូលនិធិអាកាសធាតុបៃតងគឺបទដ្ឋានអនុវត្តន៍ការងារផ្នែកបរិស្ថាន និងសង្គមរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)។ ដោយសារតែធនាគារអភិវឌ្ឍន៍អាស៊ីជាស្ថាប័នដែលទទួលស្គាល់ដោយមូលនិធិអាកាសធាតុបៃតង សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពារ និងនីតិវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅកម្រិតស្ថាប័ន បន្ស៊ីគ្នានឹងបទដ្ឋានបរិស្ថាន សុខភាព និងសុវត្ថិភាពរបស់មូលនិធិអាកាសធាតុបៃតង។

[5] ADB, ILO. 2006. សៀវភៅណែនាំស្តីពីបទដ្ឋានការងារសំខាន់ៗ ទីក្រុងម៉ានីល

## ២.ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមសម្រាប់កម្មវិធីស្តារសេដ្ឋកិច្ចបែតងនៃកម្មវិធីហិរញ្ញប្បទានបែតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន

### ក.កម្មវត្ថុនៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

24. សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានគោលបំណងលើកកម្ពស់និរន្តរភាពនៃលទ្ធផលគម្រោងតាមរយៈការការពារបរិស្ថាន និងមនុស្សពីផលប៉ះពាល់អវិជ្ជមានដែលអាចបណ្តាលមកពីគម្រោង។ សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពារចែងពីគោលបំណងគោលនយោបាយ ទំហំ ការជម្រុញ និងគោលការណ៍សម្រាប់ការការពារផ្នែកសំខាន់ៗ ៣ ជាអាទិ៍ ការការពារបរិស្ថាន (គោលការណ៍គោលនយោបាយ ១១ ចំណុច) ការការពារការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត (គោលការណ៍គោលនយោបាយ ១២ ចំណុច) និងការការពារក្រុមជនជាតិដើមភាគតិច (គោលការណ៍គោលនយោបាយ ៩ ចំណុច)។

25. កម្មវត្ថុនៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី[6] មានដូចតទៅ ៖

- ចៀសវាងផលប៉ះពាល់អវិជ្ជមានរបស់គម្រោងចំពោះបរិស្ថាន និងក្រុមមនុស្សរងផលប៉ះពាល់ ប្រសិនបើអាច
- បន្ធូរបន្ថយ កាត់បន្ថយ និង/ឬប៉ះប៉ូវសងនូវផលប៉ះពាល់អវិជ្ជមានរបស់គម្រោងចំពោះបរិស្ថាន និងក្រុមមនុស្សរងផលប៉ះពាល់ដោយសារគម្រោង ប្រសិនបើការបញ្ចៀសមិនអាចធ្វើទៅបាន និង
- ជួយអ្នកខ្ចី/អតិថិជនពង្រឹងប្រព័ន្ធការពាររបស់ពួកគេ និងអភិវឌ្ឍសមត្ថភាពគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម។

26. ផ្អែកលើចំណុចនេះ គោលបំណងនៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម រួមមាន ៖

- ការបញ្ចៀសផលប៉ះពាល់ និង/ឬហានិភ័យអវិជ្ជមានដែលអាចកើតឡើងដោយផ្ទាល់ ប្រយោល និងត្រួតស៊ីគ្នា ដោយសារគម្រោងដែលគាំទ្រដោយក្របខណ្ឌនេះ
- ការកាត់បន្ថយ ឬបន្ធូរបន្ថយផលប៉ះពាល់/ហានិភ័យអវិជ្ជមានផ្នែកបរិស្ថាន និងសង្គម

---

[6] ធនាគារអភិវឌ្ឍន៍អាស៊ីគោរពតាមកម្មវត្ថុនៃគោលនយោបាយការពារ និងការអនុវត្តគោលនយោបាយទាំងនេះ។ ធនាគារអភិវឌ្ឍន៍អាស៊ីទទួលខុសត្រូវក្នុងការរៀបចំការអង្កេតលម្អិត និងវាយតម្លៃ តាមដាន និងត្រួតពិនិត្យគម្រោងនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោងស្របតាមគោលការណ៍ និងលក្ខខណ្ឌតម្រូវដែលមានចែងក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពារ។ តាមរយៈការគោរពតាមគោលនយោបាយការពារបរិស្ថាន និងសង្គម ធនាគារអភិវឌ្ឍន៍អាស៊ីពង្រឹងនូវទស្សនលទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃសកម្មភាព និងការសម្រេចចិត្តរបស់ខ្លួន ជួយអ្នកខ្ចី/អតិថិជនគ្រប់គ្រងផលប៉ះពាល់ និងហានិភ័យបរិស្ថាន និងសង្គម និងជម្រុញការវិនិយោគឱ្យមាននិរន្តរភាពរយៈពេលវែង។ ការប្រែក្លាយការប្តេជ្ញានេះឱ្យទៅជាលទ្ធផលជាក់ស្តែង អាស្រ័យលើកិច្ចខិតខំប្រឹងប្រែងរួមគ្នា (តែខុសប្លែកពីគ្នា) រវាងធនាគារអភិវឌ្ឍន៍អាស៊ី និងអ្នកខ្ចី/អតិថិជន។

- ការធានាថា ការកាត់បន្ថយ ឬការសម្រាលផលប៉ះពាល់ និងហានិភ័យផ្នែកបរិស្ថាន និងសង្គមបំពេញតាមលក្ខខណ្ឌតម្រូវនៃច្បាប់ និងបទប្បញ្ញត្តិជាតិ និងលក្ខខណ្ឌតម្រូវសម្រាប់ការពារបរិស្ថាន និងសង្គមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដោយយកលំនាំតាមការអនុវត្តល្អបំផុតជាអន្តរជាតិ
- ការតម្រែតម្រង់រដ្ឋាភិបាលរបស់អ្នកខ្ចីក្នុងការរៀបចំគម្រោង សម្រាប់ដាក់ជូនធនាគារអភិវឌ្ឍន៍អាស៊ីវាយតម្លៃ និងក្នុងការតាមដាន ការរាយការណ៍ និងការអនុវត្តវិធានការកែតម្រូវ (ប្រសិនបើមាន)
- ការធានារៀបចំយន្តការដែលមានប្រសិទ្ធភាព ដើម្បីឱ្យមានការអនុលោមតាមគោលនយោបាយការពារក្នុងពេលអនុវត្តគម្រោង និងធ្វើសកម្មភាពកែតម្រូវ ប្រសិនបើចាំបាច់
- ការអភិវឌ្ឍសមត្ថភាពស្ថាប័នដល់បុគ្គលិកផ្នែកការពារបរិស្ថាន និងសង្គមរបស់រដ្ឋាភិបាលអ្នកខ្ចីដើម្បីធានាការអនុលោមតាមគោលនយោបាយការពារ និង
- ការធ្វើយ៉ាងណាឱ្យគម្រោងទាំងអស់ដែលគាំទ្រដោយមូលនិធិរបស់មូលនិធិអាកាសធាតុបៃតង បន្សុីគ្នានឹងបទដ្ឋានបរិស្ថាន សុខភាព និងសុវត្ថិភាពរបស់មូលនិធិអាកាសធាតុបៃតង។

## តួនាទី ការទទួលខុសត្រូវ និងសមត្ថភាព

27. សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ចែងពីតួនាទី និងការទទួលខុសត្រូវរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលរបស់អ្នកខ្ចី។ រដ្ឋាភិបាលទាំងនោះត្រូវធ្វើការវាយតម្លៃបិរស្ថាន និងសង្គម រៀបចំការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមមនុស្សរងផលប៉ះពាល់ និងសហគមន៍ រៀបចំ និងអនុវត្តផែនការការពារ តាមដានការអនុវត្តផែនការទាំងនេះ និងរៀបចំ និងដាក់របាយការណ៍ពិនិត្យតាមដាន។ ធនាគារអភិវឌ្ឍន៍អាស៊ីមានតួនាទីពន្យល់ពីលក្ខខណ្ឌតម្រូវផ្នែកគោលនយោបាយដល់អ្នកខ្ចី/អតិថិជន ជួយឱ្យអ្នកខ្ចី/អតិថិជនបំពេញលក្ខខណ្ឌតម្រូវទាំងនោះក្នុងពេលដំណើរការ និងអនុវត្តគម្រោងតាមរយៈកម្មវិធីកសាងសមត្ថភាព ធានាការអង្កេតលម្អិត និងការវាយតម្លៃ និងផ្តល់ការតាមដាន និងការត្រួតពិនិត្យ។ ក្រៅពីនេះ ធនាគារអភិវឌ្ឍន៍អាស៊ីនៅតែតាមដានការអនុលោមតាមគោលនយោបាយការពារក្នុងពេលអនុវត្តគម្រោង។ របាយការណ៍បញ្ចប់គម្រោង និងរបាយការណ៍វាយតម្លៃការអនុវត្តការងារក្នុងគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី រួមបញ្ចូលការវាយតម្លៃការអនុវត្តគោលនយោបាយការពារ។

## លក្ខខណ្ឌតម្រូវលើការគ្រប់គ្រងការការពារសម្រាប់រដ្ឋាភិបាល

28. ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ត្រូវបានដាក់បញ្ចូលពេញលេញជាមួយលក្ខខណ្ឌតម្រូវក្នុងវដ្តគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ដំណើរការអង្កេតលម្អិតត្រូវបានធ្វើឡើងតាំងពីដើមទីក្នុងវដ្តគម្រោង នៅពេលពិចារណាពីគម្រោងដែលត្រូវទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី។ ប្រសិនបើមិនអាចបំពេញការអនុលោមតាមលក្ខខណ្ឌតម្រូវសម្រាប់ការពារទាំងអស់របស់ធនាគារអភិវឌ្ឍន៍អាស៊ីបានទេ គម្រោងនឹងមិនទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ីឡើយ និងមិនអាចមានលទ្ធភាពទទួលបានហិរញ្ញប្បទានក្រោមកម្មវិធី

ស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ានទេ។ សម្រាប់គម្រោងទាំងអស់ដែលផ្តល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី ដំណើរការដែលមានពិពណ៌នាក្នុងក្របខណ្ឌនេះនៅតែបន្តធ្វើឡើងរហូតដល់រដ្ឋាភិបាលបញ្ចប់ការចូលរួមក្នុងគម្រោងនេះ។

29. នីតិវិធីដែលត្រូវអនុវត្តតាមក្រោមក្របខណ្ឌនេះ ត្រូវបានសង្ខេប និងពិពណ៌នាលម្អិតក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ជំហានសំខាន់ៗរួមមានការត្រួតពិនិត្យ ការចាត់ចំណាត់ថ្នាក់ ការអង្កេតលម្អិត ការតាមដានអនុលោមភាព និងការរាយការណ៍។ ជំហានទាំងអស់នេះត្រូវបានរៀបរាប់ក្នុងផ្នែកខាងក្រោម។ គំរូឯកសារ និងការណែនាំសម្រាប់ការរៀបចំការវាយតម្លៃផលប៉ះពាល់បរិស្ថាន ការត្រួតពិនិត្យបរិស្ថានជំហានដំបូង ផែនការតាំងទីលំនៅជាថ្មី និងផែនការក្រុមជនជាតិដើមភាគតិច[7] មានបង្ហាញក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ដោយសារតែការត្រួតពិនិត្យ និងការចាត់ចំណាត់ថ្នាក់របស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាចំណុចស្នូលក្នុងការគូសបញ្ជាក់ពីប្រភេទដាក់លាក់នៃការវាយតម្លៃ/ផែនការ និងការរាយការណ៍ចាំបាច់ អ្នកខ្ចី/អតិថិជននឹងត្រូវបានណែនាំមិនឱ្យរៀបចំផែនការ មុនការអនុម័តលើការចាត់ចំណាត់ថ្នាក់គម្រោងដោយធនាគារអភិវឌ្ឍន៍អាស៊ីឡើយ។

30. ក្នុងការអនុវត្តសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងមានការវាយតម្លៃគោលនយោបាយ បទបញ្ញា និងបទដ្ឋានជាតិស្តីពីបរិស្ថាន ការតាំងទីលំនៅជាថ្មី និងក្រុមជនជាតិដើមភាគតិចនៅកម្រិតគម្រោង។ ក្រៅពីនេះ នឹងមានការវាយតម្លៃសមត្ថភាពអនុវត្តន៍របស់អ្នកខ្ចីផងដែរ។ នៅពេលរកឃើញគម្លាត ធនាគារអភិវឌ្ឍន៍អាស៊ីអាចគាំទ្រដល់ការកសាងសមត្ថភាពទៅតាមភាពចាំបាច់។

## ខ.នីតិវិធីស្តីពីការការពារ

31. លក្ខខណ្ឌតម្រូវ និងដំណើរការដែលត្រូវបានពិពណ៌នាក្នុងឯកសារនេះ បង្ហាញពីនីតិវិធីដែលត្រូវគោរពតាមក្នុងការអនុវត្តសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងទៅតាមការតម្រូវដោយអន្តរការីហិរញ្ញវត្ថុ (FI)[8]។ ធនាគារអភិវឌ្ឍន៍អាស៊ីតម្រូវឱ្យអន្តរការីហិរញ្ញវត្ថុគោរពតាមនីតិវិធីស្តីពីការការពារដែលមានរៀបរាប់ក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពារនេះ ដូចជា ១) នីតិវិធីនៃការត្រួតពិនិត្យ ការចាត់ចំណាត់ថ្នាក់ និងការវាយតម្លៃ ២) ឯកសារស្តីពីការការពារ (ឧ. ការវាយតម្លៃផលប៉ះពាល់បរិស្ថាន ការត្រួតពិនិត្យបរិស្ថានជំហានដំបូង ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងផែនការក្រុមជនជាតិដើមភាគតិច)

[7] ពាក្យថា "ក្រុមជនជាតិដើមភាគតិច" ត្រូវបានប្រើប្រាស់ជាទូទៅសំដៅលើក្រុមវប្បធម៌ សង្គម និងក្រុមងាយរងគ្រោះខុសៗគ្នាដែលមានភិនភាគសម្គាល់ដូចតទៅ ១) ការទទួលស្គាល់ដោយខ្លួនឯងថាជាសមាជិកនៃក្រុមវប្បធម៌ជនជាតិដើម ហើយការទទួលស្គាល់អត្តសញ្ញាណនេះត្រូវបានទទួលស្គាល់ពីអ្នកដទៃ ២) ភ្ជាប់រួមគ្នានឹងតំបន់ភូមិសាស្ត្ររស់នៅ ឬដែនដីដូនតាដែលស្ថិតក្នុងតំបន់គម្រោង និងធនធានធម្មជាតិក្នុងតំបន់ជំរក និងដែនដីទាំងនេះ (៣) មានស្ថាប័ននយោបាយ សង្គម សេដ្ឋកិច្ច ឬវប្បធម៌ ដាច់ដោយឡែកពីសង្គម និងវប្បធម៌ជនជាតិភាគច្រើន និង ៥) ប្រើភាសាដោយឡែក ដែលជាទូទៅខុសពីភាសាផ្លូវការរបស់ប្រទេស ឬតំបន់ (ADB SPS 2009)។

[8] ADB SPS (2009) សេចក្តីបន្ថែម ៤ ៖ លក្ខខណ្ឌតម្រូវពិសេស ៤ ៖ លក្ខខណ្ឌតម្រូវពិសេសសម្រាប់ទម្រង់ហិរញ្ញវត្ថុផ្សេងៗ សៀវភៅណែនាំប្រតិបត្តិការ (គោលនយោបាយធនាគារ) OM Section D6/BP (Dec 2003)

៣) សមត្ថភាពរបស់បុគ្គលិក និង ៤) ការតាមដាន និងការរាយការណ៍សម្រាប់ប្រភេទហានិភ័យ ក, ខ និង គ (តារាង ២)។

## ការត្រួតពិនិត្យ និងចាត់ចំណាត់ថ្នាក់

32. ធនាគារអភិវឌ្ឍន៍អាស៊ីត្រួតពិនិត្យគម្រោងទាំងអស់ ដើម្បីកំណត់ប្រភេទនៃការការពារបរិស្ថាន និងសង្គម ដូចមានបង្ហាញក្នុងតារាង ២។ សម្រាប់តំណភ្ជាប់ទម្រង់សម្រាប់ការចាត់ចំណាត់ថ្នាក់ដែលប្រើប្រាស់ដោយបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី សូមមើលឧបសម្ព័ន្ធ ១។

**តារាង ២ ៖ ការត្រួតពិនិត្យ និងចាត់ចំណាត់ថ្នាក់ដោយធនាគារអភិវឌ្ឍន៍អាស៊ីលើហានិភ័យបរិស្ថាន ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងក្រុមជនជាតិដើមភាគតិច**

| |
|---|
| **បរិស្ថាន ៖** ចំណាត់ថ្នាក់គម្រោងត្រូវកំណត់ដោយសមាសភាគប៉ះពាល់បរិស្ថាន ដោយរួមបញ្ចូលទាំងការប៉ះពាល់ផ្ទាល់ ប្រយោល ត្រួតស៊ីគ្នា និងជាការបង្ក។ គម្រោងដាក់ស្នើនីមួយៗត្រូវទទួលការពិនិត្យយ៉ាងម៉ត់ចត់ទៅតាមប្រភេទ ទីតាំង ទំហំ ភាពងាយរងផលប៉ះពាល់ និងកម្រិតនៃការប៉ះពាល់បរិស្ថាន។ កម្រិតនៃភាពលម្អិត និងទូលំទូលាយនៃការវាយតម្លៃផលប៉ះពាល់បរិស្ថាន ឬការត្រួតពិនិត្យបរិស្ថានជំហានដំបូង ត្រូវសមាមាត្រជាមួយនឹងទំហំនៃផលប៉ះពាល់ និងហានិភ័យដែលអាចកើតមាន (ADB SPS 2009)។ |
| **ប្រភេទ ក**<br>គម្រោងដាក់ស្នើត្រូវបានរៀបចំកំណត់ជាប្រភេទ ក ប្រសិនបើគម្រោងនោះអាចមានកម្រិតនៃការប៉ះពាល់ផ្នែកបរិស្ថានខ្លាំងដែលមានលក្ខណៈចម្រុះ មិនអាចកែប្រែបាន ឬមិនធ្លាប់មានពីមុនមក។ ផលប៉ះពាល់នេះអាចនឹងមានឥទ្ធិពលលើសពីតំបន់ ឬហេដ្ឋារចនាសម្ព័ន្ធគម្រោង អាស្រ័យទៅតាមការងាររូបវន្ត។ គម្រោងនេះត្រូវការការវាយតម្លៃផលប៉ះពាល់បរិស្ថាន រួមទាំងផែនការគ្រប់គ្រងបរិស្ថាន។ |
| **ប្រភេទ ខ**<br>គម្រោងដាក់ស្នើត្រូវបានរៀបចំកំណត់ជាប្រភេទ ខ ប្រសិនបើលទ្ធភាពនៃការប៉ះពាល់ផ្នែកបរិស្ថាន មានកម្រិតទាបជាងគម្រោងប្រភេទ ក។ ការប៉ះពាល់ទាំងនោះកើតមានពិតប្រាកដតែក្នុងតំបន់ការងារ អាចកែលម្អបាន អាចងាយបង្កើតវិធានការកាត់បន្ថយការប៉ះពាល់បានងាយជាងគម្រោងប្រភេទ ក។ គម្រោងនេះត្រូវការការត្រួតពិនិត្យបរិស្ថានជំហានដំបូង រួមទាំងផែនការគ្រប់គ្រងបរិស្ថាន។ |
| **ប្រភេទ គ**<br>គម្រោងដាក់ស្នើត្រូវបានរៀបចំកំណត់ជាប្រភេទ គ ប្រសិនបើគម្រោងនោះអាចនឹងមានការប៉ះពាល់តិចតួច ឬក៏គ្មានប៉ះពាល់ផ្នែកបរិស្ថានតែម្តង។ គម្រោងនេះមិនតម្រូវឱ្យមានការវាយតម្លៃផលប៉ះពាល់បរិស្ថាន ឬការត្រួតពិនិត្យបរិស្ថានជំហានដំបូងទេ។ ទោះបីជាយ៉ាងក៏ដោយ ត្រូវមានការពិនិត្យផ្នែកបរិស្ថាន។ |
| **ប្រភេទអន្តរការីហិរញ្ញវត្ថុ**<br>គម្រោងដាក់ស្នើ ពាក់ព័ន្ធនឹងការវិនិយោគមូលនិធិរបស់ធនាគារអភិវឌ្ឍន៍អាស៊ីតាមរយៈអន្តរការីហិរញ្ញវត្ថុ។ លក្ខខណ្ឌតម្រូវមានបង្ហាញក្នុងកថាខណ្ឌ ៤៩-៥០។ |
| **ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត**<br>ចំណាត់ថ្នាក់គម្រោងមួយ ត្រូវកំណត់ដោយសមាសភាគប៉ះពាល់ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។ កម្រិតនៃភាពលម្អិត និងទូលំទូលាយនៃផែនការតាំងទីលំនៅជាថ្មី ត្រូវសមាមាត្រជាមួយនឹងទំហំនៃផលប៉ះពាល់ និងហានិភ័យដែលអាចកើតមាន (ADB SPS 2009)។ |
| **ប្រភេទ ក**<br>គម្រោងដាក់ស្នើត្រូវបានរៀបចំកំណត់ជាប្រភេទ ក ប្រសិនបើគម្រោងនោះអាចមានកម្រិតនៃផលប៉ះពាល់ខ្លាំងលើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។ ការប៉ះពាល់លើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តដោយសារគម្រោងដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានចាត់ទុកថាមានទំហំធំធេង (ប្រភេទ ក) ប្រសិនបើមានមនុស្សចាប់ពី ២០០ នាក់ឡើងទៅនឹងប្រឈមនឹងផលប៉ះពាល់ធំៗ ដែលត្រូវបានកំណត់ជា (១) ប្រជាជនដែលផ្លាស់ទីលំនៅ ឬ (២) ប្រជាជនដែលបាត់បង់ទ្រព្យសកម្មដែលមានផលិតភាពចាប់ពី ១០% ឡើងទៅ (ការបង្កើតប្រាក់ចំណូល)។<br>គម្រោងនេះត្រូវការផែនការតាំងទីលំនៅជាថ្មី រួមទាំងការវាយតម្លៃផលប៉ះពាល់សង្គម។ |

| |
|---|
| **ប្រភេទ ខ**<br>គម្រោងដាក់ស្នើត្រូវបានរៀបចំកំណត់ជាប្រភេទ ខ ប្រសិនបើគម្រោងនោះមិនបង្កការប៉ះពាល់ធំធេងលើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។ សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី កំណត់គម្រោងមួយជាគម្រោងប្រភេទ ខ ប្រសិនបើមានមនុស្សតិចជាង ២០០ នាក់នឹងប្រឈមនឹងផលប៉ះពាល់ធំៗ ដែលត្រូវបានកំណត់ជា (១) ប្រជាជនដែលផ្លាស់ទីលំនៅ ឬ (២) ប្រជាជនដែលបាត់បង់ទ្រព្យសកម្មដែលមានផលិតភាពតិចជាង ១០% (ការបង្កើតប្រាក់ចំណូល)។<br>គម្រោងនេះត្រូវការផែនការតាំងទីលំនៅឡើងវិញ រួមទាំងការវាយតម្លៃផលប៉ះពាល់សង្គម។ |
| **ប្រភេទ គ**<br>គម្រោងដាក់ស្នើត្រូវបានរៀបចំកំណត់ជាប្រភេទ គ ប្រសិនបើគម្រោងនោះមិនបង្កការប៉ះពាល់លើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។ គម្រោងនេះមិនតម្រូវឱ្យមានវិធានការបន្ថែមទៀតឡើយ។ |
| **ប្រភេទអន្តរការីហិរញ្ញវត្ថុ**<br>គម្រោងដាក់ស្នើពាក់ព័ន្ធនឹងការវិនិយោគមូលនិធិរបស់ធនាគារអភិវឌ្ឍន៍អាស៊ីតាមរយៈអន្តរការីហិរញ្ញវត្ថុ។ លក្ខខណ្ឌតម្រូវមានបង្ហាញក្នុងកថាខណ្ឌ ៤៩-៥០។ |
| **ក្រុមជនជាតិដើមភាគតិច ៖** ចំណាត់ថ្នាក់គម្រោងមួយ ត្រូវបានកំណត់ដោយសមាសភាគប៉ះពាល់ក្រុមជនជាតិដើមភាគតិច។ កម្រិតនៃការប៉ះពាល់របស់គម្រោងដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីលើជនជាតិដើមភាគតិច ត្រូវបានកំណត់ដោយ (១) កម្រិតនៃការប៉ះពាល់ទៅលើ ក) សិទ្ធិប្រពៃណីរបស់ជនជាតិដើមភាគតិច និងលទ្ធភាពទទួលបានដីធ្លី និងធនធានធម្មជាតិ ខ) ស្ថានភាពសង្គមសេដ្ឋកិច្ច គ) សុចរិតភាពវប្បធម៌ និងបូរណភាពទឹកដី ឃ) សុខភាព ការអប់រំ ការចិញ្ចឹមជីវិត និងសន្តិសុខសង្គម និង ង) ការទទួលស្គាល់ចំណេះដឹងជនជាតិដើមភាគតិច និង (២) កម្រិតភាពទទួលរងគ្រោះរបស់សហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់។ កម្រិតនៃភាពលម្អិត និងទូលំទូលាយនៃផែនការក្រុមជនជាតិដើមភាគតិច ត្រូវសមាមាត្រជាមួយនឹងទំហំនៃផលប៉ះពាល់ និងហានិភ័យដែលអាចកើតមានលើក្រុមជនជាតិដើមភាគតិច (ADB SPS 2009)។ |
| **ប្រភេទ ក**<br>គម្រោងដាក់ស្នើត្រូវបានរៀបចំកំណត់ជាប្រភេទ ក ប្រសិនបើគម្រោងនោះអាចមានកម្រិតនៃផលប៉ះពាល់ខ្លាំងលើក្រុមជនជាតិដើមភាគតិច។ គម្រោងនេះត្រូវការផែនការក្រុមជនជាតិដើមភាគតិច (IPP) រួមទាំងការវាយតម្លៃផលប៉ះពាល់សង្គម។ |
| **ប្រភេទ ខ**<br>គម្រោងដាក់ស្នើត្រូវបានរៀបចំកំណត់ជាប្រភេទ ខ ប្រសិនបើគម្រោងនោះអាចមានកម្រិតនៃផលប៉ះពាល់តិចតួចលើជនជាតិដើមភាគតិច។ គម្រោងនេះត្រូវការផែនការក្រុមជនជាតិដើមភាគតិច រួមទាំងការវាយតម្លៃផលប៉ះពាល់សង្គម។ |
| **ប្រភេទ គ**<br>គម្រោងដាក់ស្នើត្រូវបានរៀបចំកំណត់ជាប្រភេទ គ ប្រសិនបើគម្រោងនោះមិនបង្កផលប៉ះពាល់លើក្រុមជនជាតិដើមភាគតិច។ គម្រោងនេះមិនតម្រូវឱ្យមានវិធានការបន្ថែមទៀតឡើយ។ |
| **ប្រភេទអន្តរការីហិរញ្ញវត្ថុ**<br>គម្រោងដាក់ស្នើពាក់ព័ន្ធនឹងការវិនិយោគមូលនិធិរបស់ធនាគារអភិវឌ្ឍន៍អាស៊ីតាមរយៈអន្តរការីហិរញ្ញវត្ថុ។ លក្ខខណ្ឌតម្រូវមានបង្ហាញក្នុងកថាខណ្ឌ ៤៩-៥០។ |

33. នៅដំណាក់កាលដំបូង គម្រោងត្រូវបានពិនិត្យធៀបនឹងតារាងសកម្មភាពវិនិយោគដែលត្រូវបានហាមឃាត់របស់ធនាគារអភិវឌ្ឍន៍អាស៊ី (SPS សេចក្តីបន្ថែម ៥)។ ប្រសិនបើគម្រោងពាក់ព័ន្ធនឹងសកម្មភាពមួយដែលត្រូវបានហាមឃាត់ គម្រោងនោះនឹងមិនអាចទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ឬគ្មានលក្ខណៈសម្បត្តិចូលរួមក្នុងកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ានឡើយ។ មិនដូច្នោះទេ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងគូសបញ្ជាក់ពីលក្ខខណ្ឌតម្រូវសម្រាប់ការពារបរិស្ថាន និងសង្គមសម្រាប់គម្រោងនេះដល់រដ្ឋាភិបាលរបស់អ្នកខ្ចី។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងវាយតម្លៃ និងអនុម័តនីតិវិធី និងរបាយការណ៍ទាំងអស់ទៅតាមការកំណត់ក្នុងឯកសារនេះ។

34. នៅដំណាក់កាលដំបូងនៃវដ្តគម្រោង (ជាទូទៅ នៅដំណាក់កាលកំណត់អត្តសញ្ញាណគម្រោង) ធនាគារអភិវឌ្ឍន៍អាស៊ីនឹងពិគ្រោះជាមួយរដ្ឋាភិបាលរបស់អ្នកខ្ចីដើម្បីត្រួតពិនិត្យ និងចាត់ចំណាត់ថ្នាក់គម្រោងដោយផ្អែក

លើទំហំនៃផលប៉ះពាល់ និងហានិភ័យដែលអាចកើតមាន។ តារាងផ្ទៀងផ្ទាត់ការវាយតម្លៃរហ័សផ្អែកតាមវិស័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានប្រើប្រាស់ដើម្បីសម្រួលដល់ការត្រួតពិនិត្យ និងការចាត់ចំណាត់ថ្នាក់។ នឹងមានការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន ផលប៉ះពាល់នៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងផលប៉ះពាល់លើក្រុមជនជាតិដើមភាគតិច។ តារាងផ្ទៀងផ្ទាត់នេះនឹងគូសបញ្ជាក់ពីទំហំនៃផលប៉ះពាល់ដែលពាក់ព័ន្ធនឹងគម្រោងដោយកំណត់គម្រោងជាប្រភេទ ក, ខ ឬ គ (តារាង ២ និង ៣)។ ប្រសិនបើគម្រោងពាក់ព័ន្ធនឹងការវិនិយោគមូលនិធិតាមរយៈអន្តរការីហិរញ្ញវត្ថុ គម្រោងនឹងត្រូវបានកំណត់ជាប្រភេទអន្តរការីហិរញ្ញវត្ថុ។

## ការត្រួតពិនិត្យ និងការចាត់ចំណាត់ថ្នាក់ការការពារបរិស្ថាន

35. លក្ខខណ្ឌតម្រូវ និងដំណើរការដែលត្រូវបានពិពណ៌នាក្នុងឯកសារនេះ បង្ហាញពីនីតិវិធីសង្ខេបដែលត្រូវគោរពតាម ក្នុងពេលអនុវត្តសេចក្ដីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ចំណែកការពិពណ៌នាទាំងស្រុង មានបង្ហាញក្នុងសេចក្ដីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

36. ធនាគារអភិវឌ្ឍន៍អាស៊ីនឹងពិគ្រោះជាមួយរដ្ឋាភិបាលរបស់អ្នកខ្ចីដើម្បីត្រួតពិនិត្យ និងចាត់ចំណាត់ថ្នាក់គម្រោងដោយផ្អែកលើទំហំនៃផលប៉ះពាល់ និងហានិភ័យដែលអាចកើតមានលើបរិស្ថាន។ តារាងផ្ទៀងផ្ទាត់ការវាយតម្លៃរហ័សផ្អែកតាមវិស័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានប្រើប្រាស់ដើម្បីសម្រួលដល់ការត្រួតពិនិត្យ និងការចាត់ចំណាត់ថ្នាក់ (សូមមើលឧបសម្ព័ន្ធ ១)។ ផ្អែកតាមការវាយតម្លៃរហ័ស ធនាគារអភិវឌ្ឍន៍អាស៊ីនឹងកំណត់ប្រភេទបរិស្ថានទៅតាមប្រភេទដែលរៀបរាប់ក្នុងតារាង ២។

37. សម្រាប់គម្រោងទាំងអស់ រដ្ឋាភិបាលរបស់អ្នកខ្ចីនឹងខិតខំគោរពតាមលក្ខខណ្ឌតម្រូវទាំងអស់ក្នុងបទប្បញ្ញត្តិជាតិជាធរមាន។

38. ប្រសិនបើគម្រោងត្រូវបានកំណត់ជាប្រភេទ ក ការរៀបចំការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងការចុះអង្កេតនៅមូលដ្ឋាន នឹងរួមបញ្ចូលការពិគ្រោះយោបល់ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ហើយនឹងមានការដាក់ពង្រាងការវាយតម្លៃផលប៉ះពាល់បរិស្ថាន (ភាសាអង់គ្លេស) ជូនធនាគារអភិវឌ្ឍន៍អាស៊ីវាយតម្លៃ។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងតម្រូវឱ្យមានការបង្ហាញរបាយការណ៍ព្រាងស្ដីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ក្នុងគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងរយៈពេលយ៉ាងតិច ១២០ ថ្ងៃ មុនការអនុម័តគម្រោង។ ក្នុងករណីដែលគម្រោងឈានដល់ដំណាក់កាលខ្ពស់ រដ្ឋាភិបាលរបស់អ្នកខ្ចីត្រូវពិនិត្យឡើងវិញលើការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន និងឯកសារគាំទ្រផ្សេងទៀត រួមទាំងរបាយការណ៍ស្ដីពីការពិគ្រោះយោបល់សាធារណៈ។ ប្រសិនបើមានគម្លាតក្នុងលក្ខខណ្ឌតម្រូវរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងមានការរៀបចំផែនការសកម្មភាពកែតម្រូវ (CAP) ដែលត្រូវសម្រេចជាមួយធនាគារអភិវឌ្ឍន៍អាស៊ី។ គំរូរបាយការណ៍ស្ដីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន មានបង្ហាញក្នុងសេចក្ដីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (SPS សេចក្ដីបន្ថែម ១)។

39. សម្រាប់គម្រោងប្រភេទ ខ នឹងត្រូវមានការត្រួតពិនិត្យបរិស្ថានជំហានដំបូង និងផែនការគ្រប់គ្រងបរិស្ថាន (ភាសាអង់គ្លេស)។ ក្នុងករណីដែលគម្រោងឈានដល់ដំណាក់កាលខ្ពស់ រដ្ឋាភិបាលរបស់អ្នកខ្ចីនឹងត្រូវពិនិត្យឡើង

វិញលើរបាយការណ៍មានស្រាប់ (ការវាយតម្លៃថ្នាក់ជាតិ) និងឯកសារគាំទ្រផ្សេងទៀត ដូចជា របាយការណ៍ស្តីពីការពិគ្រោះយោបល់សាធារណៈ។ របាយការណ៍ដែលត្រូវបានអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ីនឹងត្រូវបានបង្ហោះក្នុងគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ប្រសិនបើមានគម្លាតក្នុងលក្ខខណ្ឌតម្រូវរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនឹងមានការរៀបចំផែនការសកម្មភាពកែតម្រូវ ដែលត្រូវអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីបំបាត់គម្លាត និងធ្វើបច្ចុប្បន្នភាពរបាយការណ៍។ គំរូរបាយការណ៍ស្តីពីការត្រួតពិនិត្យបរិស្ថានជំហានដំបូង មានបង្ហាញក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (SPS សេចក្តីបន្ថែម ១)។

## ការត្រួតពិនិត្យ និងការចាត់ចំណាត់ថ្នាក់ការការពារសង្គម ៖ ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងក្រុមជនជាតិដើមភាគតិច

40. លក្ខខណ្ឌតម្រូវ និងដំណើរដែលមានពិពណ៌នាក្នុងឯកសារនេះ បង្ហាញពីនីតិវិធីសង្ខេបដែលត្រូវគោរពតាមក្នុងពេលអនុវត្តសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ចំណែកការពិពណ៌នាទាំងស្រុងមានបង្ហាញក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

41. សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី តម្រូវឱ្យរដ្ឋាភិបាលរបស់អ្នកខ្ចីវាយតម្លៃរបាយការណ៍គម្រោង ដើម្បីវិភាគផលប៉ះពាល់ដែលអាចកើតមានលើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងផលប៉ះពាល់លើក្រុមជនជាតិដើមភាគតិច។ រដ្ឋាភិបាលត្រូវធ្វើការអង្កេតលម្អិតពីសង្គម រួមទាំងការចុះតាមទីតាំង ១ ឬច្រើនលើក ការបញ្ជាក់អះអាងព័ត៌មានស្តីពីផលប៉ះពាល់ដែលអាចកើតមាន។ ការអង្កេតលម្អិតដំបូង ត្រូវបានធ្វើឡើងជាមួយនឹងការបំពេញតារាងផ្ទៀងផ្ទាត់ការវាយតម្លៃហ័សលើការការពារសង្គមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវធានាថា រដ្ឋាភិបាលរបស់អ្នកខ្ចីដោះស្រាយគម្លាតដែលមាន និងជូនដំណឹងដល់ធនាគារអភិវឌ្ឍន៍អាស៊ីអំពីការកែប្រែនានា។ ការអង្កេតលម្អិតជាដំណើរការបន្តជាប់ និងកាន់តែស៊ីជម្រៅប្រសិនបើអនុវត្តអនុគម្រោងប្រភេទ ក។

42. ផ្អែកលើតារាងផ្ទៀងផ្ទាត់ការត្រួតពិនិត្យរហ័សលើការការពារសង្គម រដ្ឋាភិបាលរបស់អ្នកខ្ចីនឹងស្នើឱ្យមានការដាក់ពិន្ទុលើការចាត់ចំណាត់ថ្នាក់ ដោយផ្អែកលើនិយមន័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (SPS 2009) និងកត់ត្រាទុកដោយប្រើទម្រង់សម្រាប់ការកំណត់ប្រភេទ។

43. ប្រសិនបើគម្រោងត្រូវបានកំណត់ជាប្រភេទ ក សម្រាប់ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត (IR) ធនាគារអភិវឌ្ឍន៍អាស៊ីតម្រូវឱ្យរដ្ឋាភិបាលរបស់អ្នកខ្ចី សហការជាមួយទីប្រឹក្សាឯករាជ្យដើម្បីរៀបចំផែនការតាំងទីលំនៅជាថ្មីលម្អិត (RP)។ គំរូផែនការតាំងទីលំនៅជាថ្មីត្រូវបានដាក់បញ្ចូលក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (SPS សេចក្តីបន្ថែម ២)។ ចាំបាច់ត្រូវដាក់បញ្ចូលធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការពិគ្រោះយោបល់នៅពេលរៀបចំផែនការតាំងទីលំនៅជាថ្មី និងការចុះអង្កេតនៅមូលដ្ឋាន។ ពង្រាងផែនការតាំងទីលំនៅជាថ្មី (ភាសាអង់គ្លេស) នឹងត្រូវបានវាយតម្លៃដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ពង្រាង និងផែនការតាំងទីលំនៅជាថ្មីចុងក្រោយនឹងត្រូវបានបង្ហោះក្នុងគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ក្នុងករណីដែលគម្រោង

ឈានដល់ដំណាក់កាលខ្ពស់ រដ្ឋាភិបាលនឹងវាយតម្លៃផែនការតាំងទីលំនៅជាថ្មី និងឯកសារគាំទ្រផ្សេងទៀត ដូចជារបាយការណ៍ស្តីពីការពិគ្រោះយោបល់សាធារណៈ។ ប្រសិនបើមានគម្លាតក្នុងលក្ខខណ្ឌតម្រូវរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវរៀបចំផែនការសកម្មភាពកែតម្រូវ (CAP) ដែលត្រូវសម្រេចជាមួយធនាគារអភិវឌ្ឍន៍អាស៊ី។ ប្រសិនបើគម្រោងត្រូវបានកំណត់ជាប្រភេទ ខ សម្រាប់ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត (តារាង ២ ៖ ការត្រួតពិនិត្យ និងចាត់ចំណាត់ថ្នាក់ហានិភ័យ) គម្រោងនេះត្រូវការផែនការតាំងទីលំនៅជាថ្មី និងអនុវត្តតាមនីតិវិធីសម្រាប់គម្រោងប្រភេទ ក។

44. ផ្អែកតាមសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី រដ្ឋាភិបាលរបស់អ្នកខ្ចីនឹងបញ្ចៀសការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តប្រសិនបើអាចធ្វើទៅបាន កាត់បន្ថយការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត តាមរយៈការសិក្សារកមើលជម្រើសគម្រោង និងការរចនាប្លង់ផ្សេងទៀត លើកស្ទួយ (ឬយ៉ាងហោចណាស់ស្តារ) មធ្យោបាយចិញ្ចឹមជីវិតរបស់អ្នកបាត់បង់លំនៅដ្ឋានឱ្យបានក្នុងកម្រិតមួយប្រហាក់ប្រហែលនឹងកម្រិតនៅមុនពេលមានគម្រោងអភិវឌ្ឍន៍ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ជនក្រីក្រដែលត្រូវផ្លាស់ទីលំនៅ និងក្រុមងាយរងគ្រោះផ្សេងទៀត។ គោលនយោបាយការពារការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត គ្របដណ្តប់លើការផ្លាស់ទីលំនៅរូបវន្ត (ប្តូរទីតាំង បាត់បង់ដីលំនៅដ្ឋាន ឬការបាត់បង់ទីជំរក) និងការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ច (បាត់បង់ដី ទ្រព្យសកម្ម សិទ្ធប្រើប្រាស់ទ្រព្យសកម្ម ប្រភពប្រាក់ចំណូល ឬមធ្យោបាយចិញ្ចឹមជីវិត) ដោយសារតែ (១) លទ្ធកម្មដីដោយមិនស្ម័គ្រចិត្ត ឬ (២) ការកំណត់ដោយមិនស្ម័គ្រចិត្តក្នុងការប្រើប្រាស់ដី ឬសិទ្ធិប្រើប្រាស់ឧទ្យានជាតិ និងតំបន់ការពារធម្មជាតិដែលកំណត់ដោយច្បាប់។ គោលនយោបាយការពារនេះ កំណត់មើលថាតើការបាត់បង់ និងការកំណត់ដោយដោយមិនស្ម័គ្រចិត្តនោះ មានលក្ខណៈទាំងស្រុង ឬដោយផ្នែក មានលក្ខណៈជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្ន។ ចំណុចសំខាន់ ត្រូវគោរពតាមបទបញ្ញាទាំងអស់ក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០០៩)។

45. ប្រសិនបើគម្រោងត្រូវបានកំណត់ជាប្រភេទ ក សម្រាប់ជនជាតិដើមភាគតិច រដ្ឋាភិបាលរបស់អ្នកខ្ចីនឹងរៀបចំផែនការលម្អិតស្តីពីក្រុមជនជាតិដើមភាគតិច (IPP)។ គំរូផែនការក្រុមជនជាតិដើមភាគតិចត្រូវបានដាក់បញ្ចូលក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (SPS សេចក្តីបន្ថែម ២)។ ការរៀបចំផែនការក្រុមជនជាតិដើមភាគតិច និងការចុះអង្កេតនៅមូលដ្ឋាន នឹងរួមបញ្ចូលការពិគ្រោះជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងការផ្តល់ពង្រាងផែនការនេះជាភាសាអង់គ្លេសសម្រាប់ដាក់ជូនធនាគារអភិវឌ្ឍន៍អាស៊ីវាយតម្លៃ។ ពង្រាង និងផែនការក្រុមជនជាតិដើមភាគតិចចុងក្រោយ នឹងត្រូវបានបង្ហោះក្នុងគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ប្រសិនបើគម្រោងត្រូវបានកំណត់ជាប្រភេទ ខ (តារាង ២ ៖ ការត្រួតពិនិត្យ និងចាត់ចំណាត់ថ្នាក់ហានិភ័យ) គម្រោងនេះត្រូវការផែនការក្រុមជនជាតិដើមភាគតិច និងអនុវត្តតាមនីតិវិធីសម្រាប់គម្រោងប្រភេទ ក។ នឹងមានការផ្សព្វផ្សាយផែនការក្រុមជនជាតិដើមភាគតិចសម្រាប់គម្រោងប្រភេទ ខ ដែលត្រូវបានអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ី។

46. ផ្អែកតាមសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី រដ្ឋាភិបាលរបស់អ្នកខ្ចីនឹងរៀបចំ និងអនុវត្តគម្រោងក្នុងវិធីសាស្ត្រដែលជម្រុញការគោរពអត្តសញ្ញាណ សេចក្តីថ្លៃថ្នូរ សិទ្ធិមនុស្ស មធ្យោបាយចិញ្ចឹមជីវិត និងវប្បធម៌របស់ក្រុមជនជាតិដើមភាគតិច ដែលកំណត់ដោយក្រុមជនជាតិដើមភាគតិចដោយខ្លួនឯង ដើម្បីឱ្យពួកគេ (១) អាចទទួលបានអត្ថប្រយោជន៍សង្គម និងសេដ្ឋកិច្ចដែលសមស្របតាមវប្បធម៌របស់ពួកគេ (២) មិនរងផលប៉ះពាល់អវិជ្ជមានដែលកើតចេញពីគម្រោង និង (៣) អាចចូលរួមយ៉ាងសកម្មក្នុងគម្រោងដែលជះឥទ្ធិពលមកលើពួកគេ។ រដ្ឋាភិបាលរបស់អ្នកខ្ចីត្រូវគោរពតាមគោលនយោបាយការពារក្រុមជនជាតិដើមភាគតិច ដែលមានចែងក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០០៩)។

47. លក្ខខណ្ឌតម្រូវសម្រាប់ការពារក្រុមជនជាតិដើមភាគតិចនឹងត្រូវលើកមកអនុវត្ត ប្រសិនបើគម្រោងមានការប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលចំពោះសេចក្តីថ្លៃថ្នូរ សិទ្ធិមនុស្ស មធ្យោបាយចិញ្ចឹមជីវិត ឬវប្បធម៌របស់ក្រុមជនជាតិដើមភាគតិច ឬប៉ះពាល់ដល់ទឹកដី ឬធនធានធម្មជាតិ ឬវប្បធម៌ដែលក្រុមជនជាតិដើមភាគតិចកាន់កាប់ ប្រើប្រាស់ រស់នៅ ឬអះអាងថាជាទឹកដីដូនតា ឬទ្រព្យសកម្មរបស់ពួកគេ។ ក្នុងការពិចារណាពីភិនភាគសម្គាល់ទាំងនេះ ច្បាប់ជាតិ ទម្លាប់អនុវត្ត និងអនុសញ្ញាអន្តរជាតិផ្សេងទៀតដែលរដ្ឋជាភាគី នឹងត្រូវលើកយកមកពិចារណាផងដែរ។ ក្រុមមួយដែលបាត់បង់ការផ្សារភ្ជាប់រួមគ្នានឹងតំបន់ភូមិសាស្ត្ររស់នៅ ឬដែនដីដូនតាដែលស្ថិតនៅក្នុងតំបន់គម្រោងដោយសារតែការផ្តាច់ចេញដោយមិនស្ម័គ្រចិត្ត នៅតែមានសិទ្ធិទទួលបាននៅក្រោមគោល-នយោបាយនេះ។

48. សម្រាប់គម្រោងទាំងអស់ រដ្ឋាភិបាលរបស់អ្នកខ្ចីនឹងខិតខំគោរពតាមលក្ខខណ្ឌតម្រូវថ្នាក់ជាតិដែលពាក់ព័ន្ធនឹងក្រុមជនជាតិដើមភាគតិច។

## អន្តរការីហិរញ្ញវត្ថុ

49. ចំពោះគម្រោងដែលវិនិយោគដោយមូលនិធិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឬអន្តរការីហិរញ្ញវត្ថុ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងរៀបចំការអង្កេតលម្អិតពីការការពារដើម្បីវាយតម្លៃហានិភ័យ និងផលប៉ះពាល់ដែលអាចមានចំពោះសង្គម និងបរិស្ថានដែលពាក់ព័ន្ធនឹងអន្តរការីហិរញ្ញវត្ថុដែលមានស្រាប់ និងផលប័ត្រគម្រោងដែលអាចមាននៅពេលអនាគត និងពិនិត្យមើលការប្តេជ្ញា និងសមត្ថភាពរបស់ខ្លួនក្នុងការគ្រប់គ្រងសង្គម និងបរិស្ថាន។ ប្រសិនបើការវិនិយោគរបស់អន្តរការីហិរញ្ញវត្ថុមានផលប៉ះពាល់ចំពោះសង្គម និងបរិស្ថានតិចតួច ឬគ្មានផលប៉ះពាល់អវិជ្ជមាន គម្រោងរបស់អន្តរការីហិរញ្ញវត្ថុនឹងត្រូវបានចាត់ទុកជាគម្រោងប្រភេទ គ ហើយមិនចាំបាច់អនុវត្តលក្ខខណ្ឌតម្រូវជាក់លាក់ផ្សេងទៀតឡើយ។ អន្តរការីហិរញ្ញវត្ថុផ្សេងទៀតចាំបាច់ត្រូវមាន ឬបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) ដែលមានទំហំសមាមាត្រនឹងលក្ខណៈ និងហានិភ័យនៃនៃការវិនិយោគរបស់អន្តរការីហិរញ្ញវត្ថុនៅពេលអនាគត ដែលប្រព័ន្ធនេះនឹងត្រូវរក្សាជាផ្នែកមួយប្រព័ន្ធគ្រប់គ្រងទាំងមូលរបស់អន្តរការីហិរញ្ញវត្ថុ។ ប្រព័ន្ធ

គ្រប់គ្រងបរិស្ថាន និងសង្គមនឹងត្រូវបានចងក្រងជាឯកសារ និងសម្រេចដោយធនាគារអភិវឌ្ឍន៍អាស៊ី និងអន្តរការីហិរញ្ញវត្ថុ។

50. លក្ខខណ្ឌតម្រូវលម្អិតសម្រាប់ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គមរបស់អន្តរការីហិរញ្ញវត្ថុ មានលម្អិតក្នុងសេចក្ដីបន្ថែម ៤ នៃសេចក្ដីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ អន្តរការីហិរញ្ញវត្ថុទាំងអស់នឹងធានាថា ការវិនិយោគរបស់ខ្លួនអនុលោមតាមបទប្បញ្ញត្តិ និងច្បាប់ជាតិជាធរមាន និងអនុវត្តអនុគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី ដោយផ្អែកតាមតារាងសកម្មភាពវិនិយោគដែលត្រូវបានហាមឃាត់ (ADB SPS សេចក្ដីបន្ថែម ៥)។ ប្រសិនបើអនុគម្រោងទាំងនោះអាចបង្កផលប៉ះពាល់គួរឱ្យកត់សម្គាល់លើបរិស្ថាន និងសង្គម អន្តរការីហិរញ្ញវត្ថុត្រូវធ្វើយ៉ាងណាឱ្យអនុគម្រោងទាំងនោះបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់ការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូចជា លក្ខខណ្ឌតម្រូវស្ដីពីការផ្សព្វផ្សាយព័ត៌មាន និងការពិគ្រោះយោបល់។ ក្នុងករណីទាំងនេះ អន្តរការីហិរញ្ញវត្ថុនឹងអនុវត្តអនុគម្រោងទៅតាមលក្ខខណ្ឌតម្រូវរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងដំណើរការអង្កេតលម្អិត ហើយធនាគារអភិវឌ្ឍន៍អាស៊ីនឹងជួយដល់អន្តរការីហិរញ្ញវត្ថុក្នុងការវាយតម្លៃអនុគម្រោងទាំងនេះ។ ទន្ទឹមនឹងនេះ អ្នកខ្ចីនឹងដាក់ការវាយតម្លៃផលប៉ះពាល់បរិស្ថាន ផែនការតាំងទីលំនៅជាថ្មី ឬផែនការក្រុមជនជាតិដើមភាគតិច ជូនធនាគារអភិវឌ្ឍន៍អាស៊ីសម្រេច មុននឹងអនុម័តអនុគម្រោង។

## គ.ការអង្កេតលម្អិតពីការការពារ

51. ចំពោះគម្រោងស្នើសុំហិរញ្ញប្បទាន ធនាគារអភិវឌ្ឍន៍អាស៊ីនឹងរៀបចំការវាយតម្លៃការការពារ ដែលរួមទាំងការវាយតម្លៃឯកសារការពាររបស់អ្នកខ្ចី ដែលនេះជាផ្នែកមួយនៃការអង្កេតលម្អិត។ ក្រៅពីការចងក្រងឯកសារស្ដីពីការការពារ ការអង្កេតលម្អិត និងការវាយតម្លៃការការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី សង្កត់ធ្ងន់លើការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម និងដំណើរការរៀបចំផែនការ។ ការអង្កេតលម្អិត និងការវាយតម្លៃពាក់ព័ន្ធនឹងការចុះអង្កេតនៅមូលដ្ឋាន និងការវាយតម្លៃនៅការិយាល័យ។ តាមរយៈការអង្កេតលម្អិត និងការវាយតម្លៃ ធនាគារអភិវឌ្ឍន៍អាស៊ីធានាអះអាងថា (១) រាល់ផលប៉ះពាល់ និងហានិភ័យបរិស្ថាន និងសង្គមរបស់គម្រោងត្រូវបានកំណត់ (២) វិធានការមានប្រសិទ្ធភាពក្នុងការបញ្ចៀស កាត់បន្ថយ បន្ធូរបន្ថយ ឬប៉ះប៉ូវសងនូវផលប៉ះពាល់អវិជ្ជមាន ត្រូវបានដាក់បញ្ចូលក្នុងផែនការការពារ និងប្លង់រចនាគម្រោង (៣) អ្នកខ្ចី/អតិថិជនយល់ពីគោលការណ៍គោលនយោបាយការពារ និងលក្ខខណ្ឌតម្រូវរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានចែងក្នុងសេចក្ដីថ្លែងការណ៍នៃគោលនយោបាយការពារ និងមានការប្ដេជ្ញាចិត្ត និងលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងផលប៉ះពាល់ និង/ឬហានិភ័យបរិស្ថាន និងសង្គម (៤) តួនាទីរបស់តតីយជនត្រូវបានកំណត់យ៉ាងសមស្របក្នុងផែនការការពារ និង (៥) ការពិគ្រោះយោបល់ជាមួយក្រុមមនុស្សរងផលប៉ះពាល់ត្រូវបានរៀបចំធ្វើ ស្របតាមលក្ខខណ្ឌតម្រូវរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

52. លក្ខណៈនៃការអង្កេតលម្អិត អាស្រ័យលើភាពស្មុគស្មាញរបស់គម្រោង និងផលប៉ះពាល់ដែលអាចកើតមាន។ ខណៈដែលគម្រោងប្រភេទ គ អាចផ្អែកលើការសិក្សាឯកសារពាក់ព័ន្ធ ជាទូទៅ គម្រោងប្រភេទ ខ តម្រូវឱ្យមានការ

សិក្សាឯកសារពាក់ព័ន្ធ និងការចុះអង្កេតនៅមូលដ្ឋាន ចំណែកគម្រោងប្រភេទ ក ពាក់ព័ន្ធនឹងការវាយតម្លៃពេញលេញក្នុងពេលចុះអង្កេតនៅមូលដ្ឋាន និងការចូលរួមរបស់បុគ្គលិកគម្រោងក្នុងការពិគ្រោះយោបល់សាធារណៈ។

53. របាយការណ៍ស្តីពីការអង្កេតលម្អិត និង/ឬផែនការការពារ នឹងត្រូវបានរៀបចំឡើងសម្រាប់គម្រោងប្រភេទ ក និង ខ។ គំរូឯកសារនេះមានបង្ហាញក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ចំណែកតំណភ្ជាប់ឯកសារនេះមានបង្ហាញក្នុងឧបសម្ព័ន្ធ ១។ សម្រាប់គម្រោងប្រភេទ ក រដ្ឋាភិបាលត្រូវផ្តល់ឯកសារស្តីពីបរិស្ថាន និងសង្គមតាំងពីដំបូងក្នុងដំណើរការការអង្កេតលម្អិតរបស់ខ្លួន។ ចាំបាច់ត្រូវដាក់ផែនការការពារទាំងអស់ (ការវាយតម្លៃផលប៉ះពាល់បរិស្ថាន ការត្រួតពិនិត្យបរិស្ថានជំហានដំបូង ផែនការតាំងទីលំនៅជាថ្មី ផែនការក្រុមជនជាតិដើមភាគតិច ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម) ជូនធនាគារអភិវឌ្ឍន៍អាស៊ីពិនិត្យ និងអនុម័ត។ សម្រាប់គម្រោងប្រភេទ ក នឹងមានការបង្ហាញពង្រាងការវាយតម្លៃផលប៉ះពាល់បរិស្ថានជូនក្រុមទទួលបន្ទុកបរិស្ថានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ពង្រាងឯកសារនេះនឹងត្រូវបានជួយពិនិត្យដោយនាយកដ្ឋានការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងអនុម័តដោយប្រធានផ្នែកអនុលោមភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

54. យោងតាមសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០០៩) អ្នកខ្ចីទទួលខុសត្រូវវាយតម្លៃគម្រោង និងផលប៉ះពាល់បរិស្ថាន និងសង្គម ការរៀបចំផែនការការពារ និងជួបជាមួយសហគមន៍រងផលប៉ះពាល់តាមរយៈការផ្សព្វផ្សាយព័ត៌មាន ការពិគ្រោះយោបល់ និងការចូលរួម និងគោរពតាមគោលការណ៍គោលនយោបាយ និងលក្ខខណ្ឌតម្រូវសម្រាប់ការពារទាំងអស់។ អ្នកខ្ចីនឹងផ្ញើព័ត៌មានចាំបាច់នានារួមទាំងរបាយការណ៍វាយតម្លៃ ផែនការ/ក្របខណ្ឌការពារ និងរបាយការណ៍តាមដានឱ្យធនាគារអភិវឌ្ឍន៍អាស៊ីត្រួតពិនិត្យ។ អ្នកខ្ចីត្រូវគោរពតាមច្បាប់ បទបញ្ញា និងបទដ្ឋានរបស់ប្រទេសម្ចាស់ផ្ទះ រួមទាំងកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិដែលប្រទេសម្ចាស់ផ្ទះត្រូវបំពេញផងដែរ។ លើសពីនេះ អ្នកខ្ចី/អតិថិជនត្រូវអនុវត្តវិធានការការពារដែលបានព្រមព្រៀងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីបំពេញតាមគោលការណ៍គោលនយោបាយ និងលក្ខខណ្ឌតម្រូវដែលមានចែងក្នុងលក្ខខណ្ឌតម្រូវសម្រាប់ការពារ (១-៤)។ ដើម្បីធានាថា អ្នកម៉ៅការអនុវត្តវិធានការដែលបានព្រមព្រៀងបានត្រឹមត្រូវ អ្នកខ្ចីនឹងបញ្ចូលលក្ខខណ្ឌតម្រូវសម្រាប់ការពារក្នុងឯកសារដេញថ្លៃ និងកិច្ចសន្យាការងារសាងសង់។

**តារាង ៣ ៖ លក្ខខណ្ឌតម្រូវសម្រាប់ការពារ**

| ប្រភេទ (ការចាត់ចំណាត់ថ្នាក់ហានិភ័យ) | ការការពារបរិស្ថាន | ការការពារការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត | ការការពារក្រុមជនជាតិដើមភាគតិច |
|---|---|---|---|
| ប្រភេទ ក (អាចបង្កផលប៉ះពាល់យ៉ាងខ្លាំង) | អនុលោមតាម (១) លក្ខខណ្ឌតម្រូវសម្រាប់ការពារ ១ នៃសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០០៩) និង (២) ច្បាប់ជាតិ។<br>រៀបចំការវាយតម្លៃផលប៉ះពាល់បរិស្ថាន (ដោយមានផែនការគ្រប់គ្រងបរិស្ថាន)។ បង្ហាញព្រាងការវាយតម្លៃផលប៉ះពាល់បរិស្ថានក្នុងរយៈពេល ១២០ ថ្ងៃមុនការអនុម័តគម្រោង។ រក្សាទុកអ្នកជំនាញខាងក្រៅដែលមានគុណវុឌ្ឍិ និងបទពិសោធន៍ ដើម្បីផ្ទៀងផ្ទាត់ការអនុលោមតាម។ | អនុលោមតាម (១) លក្ខខណ្ឌតម្រូវសម្រាប់ការពារ ២ នៃសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០០៩) រួមទាំងការរៀបចំផែនការតាំងទីលំនៅជាថ្មី ដោយមានការដាក់ឯកសារវាយតម្លៃសង្គម និងវិធានការនានា (ដែលធនាគារអភិវឌ្ឍន៍អាស៊ីយល់ថាពាក់ព័ន្ធ) | អនុលោមតាម (១) លក្ខខណ្ឌតម្រូវសម្រាប់ការពារ ៣ នៃសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០០៩) និង (២) ច្បាប់ជាតិ។<br>រៀបចំ និងអនុវត្តដំណើរការដែលធនាគារអភិវឌ្ឍន៍អាស៊ីយល់ថាពាក់ព័ន្ធ។<br>ត្រូវទទួលបានការគាំទ្រយ៉ាងផុសផុលពីសហគមន៍ ដូចមានចែងក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០០៩)។<br>ត្រូវរៀបចំការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ និងចងក្រងទុកជាឯកសារ។<br>រៀបចំផែនការក្រុមជនជាតិដើមភាគតិច (IPP)។ |
| ប្រភេទ ខ (មិនសូវមានផលប៉ះពាល់ខ្លាំង) | អនុលោមតាម (១) លក្ខខណ្ឌតម្រូវនៃការការពារទី ១ នៃសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០០៩) និង (២) ច្បាប់ជាតិ។<br>ធ្វើការត្រួតពពិនិត្យបរិស្ថានដំហានដំបូង (ដោយមានផែនការគ្រប់គ្រងបរិស្ថាន)។<br>ផ្សព្វផ្សាយពីការត្រួតពិនិត្យបរិស្ថានដំហានដំបូង មុនពេលអនុម័តគម្រោង។ | អនុលោមតាម (១) លក្ខខណ្ឌតម្រូវនៃការការពារទី ២ នៃសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០០៩) និង (២) ច្បាប់ជាតិ។<br>រៀបចំផែនការតាំងទីលំនៅជាថ្មីដោយមានការវាយតម្លៃសង្គម។ | អនុលោមតាមលក្ខខណ្ឌតម្រូវសម្រាប់ការពារ ៣ នៃសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០០៩) និង (២) ច្បាប់ជាតិ។<br>រៀបចំ និងអនុវត្តដំណើរការទៅតាមភាពពាក់ព័ន្ធក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។<br>ត្រូវទទួលបានការគាំទ្រយ៉ាងផុសផុលពីសហគមន៍ ដូចមានចែងក្នុងសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០០៩)។<br>ត្រូវរៀបចំការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ និងចងក្រងទុកជាឯកសារ។<br>រៀបចំផែនការក្រុមជនជាតិដើមភាគតិច (IPP)។ |

| | | | |
|---|---|---|---|
| ប្រភេទ គ (គ្មាន ឬមានផល ប៉ះពាល់តិច) | វាយតម្លៃផលវិបាកផ្នែកបរិស្ថាន។ អនុលោមតាមច្បាប់ជាតិ។ | វាយតម្លៃថាតើមានការប៉ះពាល់លើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ឬទេ និងរៀបចំរបាយការណ៍អង្កេតលម្អិត (DDR)។ អនុលោមតាមច្បាប់ជាតិ។ | អនុលោមតាម (១) លក្ខខណ្ឌតម្រូវសម្រាប់ការពារទី ៣ នៃសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០០៩) និង (២) ច្បាប់ជាតិ។ វាយតម្លៃថាតើមានផលប៉ះពាល់លើក្រុមជនជាតិដើមភាគតិច ឬទេ និងរៀបចំរបាយការណ៍អង្កេតលម្អិត (DDR)។ អនុលោមតាមច្បាប់ជាតិ។ |
| ប្រភេទអន្តរការីហិរញ្ញវត្ថុ | ការវិនិយោគអាចបង្កហានិភ័យលើបរិស្ថាន និងសង្គម (គម្រោងប្រភេទ ក និង ខ) ៖ បង្កើតប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) ក្នុងប្រព័ន្ធគ្រប់គ្រងជារួមរបស់អន្តរការីហិរញ្ញវត្ថុ។ សម្រាប់អនុគម្រោងដែលអាចបង្កហានិភ័យខ្ពស់ ត្រូវមានការអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ីលើការវាយតម្លៃផលប៉ះពាល់បរិស្ថានមុនការអនុម័តអនុគម្រោង។ | ការវិនិយោគអាចបង្កហានិភ័យលើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត (គម្រោងប្រភេទ ក និង ខ) ៖ បង្កើតប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) ក្នុងប្រព័ន្ធគ្រប់គ្រងជារួមរបស់អន្តរការីហិរញ្ញវត្ថុ។ សម្រាប់អនុគម្រោងដែលអាចបង្កហានិភ័យខ្ពស់ ត្រូវមានការអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ីលើផែនការតាំងទីលំនៅជាថ្មី មុនការអនុម័តអនុគម្រោង។ | ការវិនិយោគអាចបង្កហានិភ័យលើជនជាតិដើមភាគតិច (គម្រោងប្រភេទ ក និង ខ) ៖ បង្កើតប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) ក្នុងប្រព័ន្ធគ្រប់គ្រងជារួមរបស់អន្តរការីហិរញ្ញវត្ថុ។ សម្រាប់អនុគម្រោងដែលអាចបង្កហានិភ័យខ្ពស់ ត្រូវមានការអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ីលើផែនការក្រុមជនជាតិដើមភាគតិចមុនការអនុម័តអនុគម្រោង។ |

## ឃ.ការផ្សព្វផ្សាយព័ត៌មាន ការពិគ្រោះយោបល់ និងការចូលរួម

55. ផ្អែកតាមសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីស្តីពីលទ្ធភាពទទួលបានព័ត៌មាន[9] ធនាគារអភិវឌ្ឍន៍អាស៊ីព្យាយាមធ្វើការជាមួយរដ្ឋាភិបាលរបស់អ្នកខ្ចីដើម្បីធានាថា រាល់ព័ត៌មានពាក់ព័ន្ធ (វិជ្ជមាន ឬអវិជ្ជមាន) អំពីការការពារបរិស្ថាន និងសង្គមត្រូវបានផ្សព្វផ្សាយទាន់ពេលវេលា នៅទីកន្លែងដែលអាចទទួលបាន និងក្នុងទម្រង់ និងភាសាដែលងាយយល់ដល់ក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងទៀត រួមទាំងសាធារណៈជន ដើម្បីឱ្យពួកគេមានឱកាសរួមចំណែកដល់ការរៀបចំ និងអនុវត្តគម្រោង។ ធនាគារអភិវឌ្ឍន៍អាស៊ី នឹងធ្វើការផ្សព្វផ្សាយឯកសារស្តីពីការការពារដូចខាងក្រោមនៅក្នុងគេហទំព័ររបស់ខ្លួន ដោយមានការរៀបចំគម្រោងនីមួយៗជាទំព័រដោយឡែកៗពីគ្នា និងក្នុងទំព័រស្តីពីគម្រោងស្តារសេដ្ឋកិច្ចបៃតងរបស់ កម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន ៖

- ចំពោះគម្រោងបរិស្ថានប្រភេទ ក រៀបចំពង្រាងរបាយការណ៍វាយតម្លៃពីការប៉ះពាល់ផ្នែកបរិស្ថានយ៉ាងហោចណាស់រយៈពេល ១២០ ថ្ងៃ មុនពេលក្រុមប្រឹក្សាភិបាលធ្វើការពិចារណា។

[9] ADB. 2018. គោលនយោបាយស្តីពីលទ្ធភាពទទួលបានព័ត៌មាន ទីក្រុងម៉ានីល ៖ https://www.adb.org/documents/access-information-policy

- រៀបចំព្រាងការវាយតម្លៃបរិស្ថាន និងត្រួតពិនិត្យក្របខណ្ឌការងារ។ ព្រាងការត្រួតពិនិត្យបរិស្ថានជំហានដំបូង ព្រាងក្របខណ្ឌ និង/ឬផែនការតាំងទីលំនៅជាថ្មី និងព្រាងក្របខណ្ឌរៀបចំផែនការ និង/ឬផែនការក្រុមជនជាតិដើមភាគតិច មុនពេលធ្វើវាយតម្លៃគម្រោង
- បញ្ចប់ ឬធ្វើបច្ចុប្បន្នភាពការវាយតម្លៃផលប៉ះពាល់បរិស្ថាន និង/ឬការត្រួតពិនិត្យបរិស្ថានជំហានដំបូង ផែនការតាំងទីលំនៅជាថ្មី និងផែនការក្រុមជនជាតិដើមភាគតិច បន្ទាប់ពីទទួលបាន
- រៀបចំផែនការស្តីពីវិធានការកែតម្រូវ ក្នុងពេលអនុវត្តគម្រោង និង
- អ្នកខ្ចី/អតិថិជនត្រូវដាក់របាយការណ៍ស្តីពីបរិស្ថាន ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងក្រុមជនជាតិដើមភាគតិច ក្នុងពេលអនុវត្តគម្រោង បន្ទាប់ពីទទួលបាន។

56. តំណភ្ជាប់របាយការណ៍ទាំងនេះអាចរកបានក្នុងគេហទំព័ររបស់មូលនិធិអាកាសធាតុបៃតង ដោយផ្អែកតាមគោលនយោបាយរបស់មូលនិធិអាកាសធាតុបៃតងស្តីពីការផ្សព្វផ្សាយព័ត៌មាន និងគោលនយោបាយបរិស្ថាន និងសង្គម។

57. សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី រៀបរាប់ពីលក្ខខណ្ឌតម្រូវសម្រាប់រដ្ឋាភិបាលរបស់អ្នកខ្ចីក្នុងការរៀបចំការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ ជាមួយអ្នកពាក់ព័ន្ធផ្សេងៗ។ ការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យគឺជាដំណើរការដែល (១) ចាប់ផ្តើមនៅដើមដំណាក់កាលនៃការរៀបចំគម្រោង និងបន្តធ្វើជាប់ជានិច្ចនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង (២) ធ្វើការផ្តល់ព័ត៌មានពាក់ព័ន្ធ និងសមស្របទាន់ពេលវេលា និងជាព័ត៌មានដែលក្រុមមនុស្សរងផលប៉ះពាល់អាចរកបាន និងអាចយល់បានដោយងាយស្រួល (៣) ធ្វើឡើងនៅក្នុងបរិយាកាសដែលគ្មានការគំរាមកំហែង និងបង្ខិតបង្ខំ (៤) មានការគិតគូរពីបញ្ហាយេនឌ័រ និងមានការតម្រែតម្រង់ទៅតាមតម្រូវការក្រុមទន់ខ្សោយ និងងាយរងគ្រោះ និង (៥) ជម្រុញឱ្យមានការបញ្ចូលគំនិតយោបល់របស់ក្រុមរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធក្នុងការធ្វើការសេចក្តីសម្រេចចិត្តពីការរចនាគម្រោង វិធានការកាត់បន្ថយផលប៉ះពាល់ ការចែករំលែកអត្ថប្រយោជន៍ និងឱកាសដែលបានមកពីការអភិវឌ្ឍ និងបញ្ហាអនុវត្តន៍គម្រោង។ រដ្ឋាភិបាលរបស់អ្នកខ្ចីនឹងបញ្ចូលសហគមន៍ ក្រុម ឬក៏ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោងដែលបានស្នើ និងជាមួយសង្គមស៊ីវិល តាមរយៈការផ្តល់ព័ត៌មាន ការពិគ្រោះយោបល់ និងការចូលរួមដោយមានព័ត៌មាន ដោយស្របទៅនឹងហានិភ័យ និងការប៉ះពាល់ចំពោះសហគមន៍ដែលរងផលប៉ះពាល់។

58. ចំពោះគម្រោងដែលមានការប៉ះពាល់បរិស្ថាន ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ឬការប៉ះពាល់ចំពោះក្រុមជនជាតិដើមភាគតិចក្នុងកម្រិតខ្ពស់ ក្រុមការងារធនាគារអភិវឌ្ឍន៍អាស៊ីនឹងចូលរួមនៅក្នុងសកម្មភាពពិគ្រោះយោបល់ដើម្បីយល់ពីកង្វល់របស់ក្រុមមនុស្សរងផលប៉ះពាល់ និងធានាថាមានការបញ្ចូលកង្វល់ទាំងនោះទៅក្នុងការរៀបចំគម្រោង និងផែនការការពារ។

59. ដំណើរការពិគ្រោះយោបល់នឹងប្រើប្រាស់មធ្យោបាយពិគ្រោះយោបល់ផ្លូវការ និងក្រៅផ្លូវការជាច្រើន ដូចជាបទសម្ភាសន៍ស៊ីជម្រៅ កិច្ចប្រជុំសាធារណៈ កិច្ចពិភាក្សាក្រុមគោលដៅ។ល។ ឧទាហរណ៍នៃអ្នកផ្តល់ព័ត៌មានសំខាន់ៗដែលត្រូវពិគ្រោះយោបល់ក្នុងពេលរៀបចំ និងអនុវត្តគម្រោង រួមបញ្ចូលអ្នកពាក់ព័ន្ធដូចខាងក្រោម ៖

(i) មេគ្រួសារ និងសមាជិកគ្រួសារដែលអាចរងផលប៉ះពាល់
(ii) គ្រួសាររងផលប៉ះពាល់ដែលស្ថិតក្នុងក្រុមងាយរងគ្រោះ
(iii) សហគមន៍ម្ចាស់ផ្ទះ
(iv) ក្រុមជនជាតិដើមភាគតិច (សូមមើលផងដែរ ADB SPS)
(v) ស្ត្រីដែលស្ថិតក្នុងសហគមន៍រងផលប៉ះពាល់ និងសហគមន៍ម្ចាស់ផ្ទះ
(vi) អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន (ប្រសិនបើមាន)
(vii) ទីភ្នាក់ងារ និងនាយកដ្ឋាន/មន្ទីរពាក់ព័ន្ធរបស់រដ្ឋាភិបាល

60. យោងតាមសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្ត្រីនឹងត្រូវបានជម្រុញឱ្យចូលរួមក្នុងការពិគ្រោះយោបល់សាធារណៈ នៅកម្រិត និងដំណាក់កាលផ្សេងៗនៃការរៀបចំគម្រោង និងទៅតាមការរៀបចំដែលនឹងបង្កើនសមត្ថភាពរបស់ស្ត្រីក្នុងការចូលរួមក្នុងកិច្ចប្រជុំទាំងនេះ។ អ្នកខ្ចីនឹងធ្វើយ៉ាងណាឱ្យមានការយកចិត្តទុកដាក់ និងលើកឡើងពីទស្សនៈរបស់ក្រុមមនុស្សរងផលប៉ះពាល់ ជាពិសេសក្រុមងាយរងគ្រោះ ក្នុងផែនការពាក់ព័ន្ធ។

61. ប្រសិនបើគម្រោងពាក់ព័ន្ធនឹងលទ្ធកម្មដី និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ត្រូវរៀបចំ និងអនុវត្តផែនការនីមួយៗស្តីពីការដោះស្រាយផលប៉ះពាល់ក្រោមការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធ ជាមួយក្រុមមនុស្សរងផលប៉ះពាល់ និងធ្វើការអង្កេត និងរៀបចំកិច្ចប្រជុំសហគមន៍។ នឹងមានការកំណត់កម្រិតនៃការផ្តល់សំណង និងជំនួយ ក្រោមការពិគ្រោះយោបល់ជាមួយក្រុមមនុស្សរងផលប៉ះពាល់ និងតំណាងរបស់ពួកគេ។ ប្រាក់សំណងនឹងត្រូវសម្រេចទៅតាមការព្រមព្រៀងជាមួយក្រុមមនុស្សរងផលប៉ះពាល់។ ព័ត៌មានស្តីពីការតាំងទីលំនៅជាថ្មី រួមទាំងការវាស់វែងការខាតបង់ ការប៉ាន់ប្រមាណលម្អិតលើតម្លៃទ្រព្យសកម្ម លក្ខណៈសម្បត្តិទទួលបានសំណង និងការផ្តល់ជូនពិសេស នីតិវិធីប្តឹងតវ៉ា ការកំណត់ពេលទូទាត់ និងកាលវិភាគផ្លាស់ទីលំនៅ នឹងត្រូវបានផ្សព្វផ្សាយដល់ក្រុមមនុស្សរងផលប៉ះពាល់។ ការផ្សព្វផ្សាយនឹងធ្វើឡើងតាមរបៀបដែលផ្តល់ភាពងាយស្រួលដល់ក្រុមមនុស្សរងផលប៉ះពាល់ ក្នុងករណីដែលពួកគេមានកម្រិតអក្ខភាពខុសៗគ្នា។ នឹងមានការបង្ហាញផែនការជាភាសាក្នុងមូលដ្ឋានដល់ក្រុមមនុស្សរងផលប៉ះពាល់ ក្នុងអំឡុងពេលសមស្របយ៉ាងតិច ៣ ខែ មុនពេលផ្លាស់ទីលំនៅ។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងវាយតម្លៃ និងអនុម័តផែនការតាំងទីលំនៅជាថ្មី មុននឹងផ្តល់មូលនិធិដល់អនុគម្រោងដែលពាក់ព័ន្ធនឹងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។

62. ផ្អែកតាមសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី រដ្ឋាភិបាលរបស់អ្នកខ្ចីនឹងរៀបចំការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ និងជនជាតិភាគតិច ដើម្បីធ្វើយ៉ាងណាឱ្យពួកគេចូលរួមក្រោយពីទទួលបានព័ត៌មានគ្រប់គ្រាន់។ រដ្ឋាភិបាលរបស់អ្នកខ្ចី

នឹងរចនា អនុវត្ត និងតាមដានសកម្មភាពដើម្បីបង្ការកុំឱ្យគម្រោងជះផលអវិជ្ជមានលើក្រុមជនជាតិដើមភាគតិច និងជនជាតិភាគតិច។ ប្រសិនបើមិនអាចបញ្ចៀសផលប៉ះពាល់បាន រដ្ឋាភិបាលនឹងខិតខំកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ឬផ្តល់សំណងគ្រប់គ្រាន់ ក៏ដូចជាផ្តល់លទ្ធភាពឱ្យជនជាតិដើមភាគតិច និងជនជាតិភាគតិចទទួលបានអត្ថប្រយោជន៍ពីអនុគម្រោង តាមរបៀបដែលសមស្របទៅតាមប្រពៃណីវប្បធម៌របស់ពួកគេ។

## ខ.ការតាមដាន និងការាយការណ៍ពីអនុលោមភាព

63. ទំហំនៃសកម្មភាពតាមដាន រួមទាំងវិសាលភាព និងសាមយិកភាព ត្រូវសមាមាត្រជាមួយនឹងហានិភ័យ និងផលប៉ះពាល់របស់គម្រោង។ រដ្ឋាភិបាលរបស់អ្នកខ្ចីត្រូវអនុវត្តវិធានការការពារ និងផែនការការពារពាក់ព័ន្ធ ក្រោមការព្រមព្រៀងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងអនុលោមតាមក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម និងផ្ញើរបាយការណ៍សាមយិកស្តីពីការតាមដានលទ្ធផលអនុវត្តការងាររបស់ពួកគេ។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងតម្រូវឱ្យរដ្ឋាភិបាលរបស់អ្នកខ្ចី ៖

- បង្កើត និងរក្សានីតិវិធីតាមដានការវិវត្តនៃការអនុវត្តផែនការការពារ
- បញ្ជាក់នូវការអនុលោមតាមវិធានការការពារ និងការវិវត្តឆ្ពោះទៅលទ្ធផលរំពឹងទុក
- កត់ត្រា និងផ្សព្វផ្សាយលទ្ធផលតាមដាន និងកំណត់នូវសកម្មភាពកែតម្រូវ និងសកម្មភាពបង្ការក្នុងរបាយការណ៍តាមដានសាមយិក
- តាមដានមើលសកម្មភាពទាំងនេះដើម្បីធានានូវការវិវត្តឆ្ពោះទៅលទ្ធផលរំពឹងទុក
- ជួលអ្នកជំនាញពីខាងក្រៅដែលមានគុណវុឌ្ឍិ និងមានបទពិសោធន៍ ឱ្យធ្វើការបញ្ជាក់លើព័ត៌មានតាមដានចំពោះគម្រោងដែលមានផលប៉ះពាល់ និងហានិភ័យធ្ងន់ធ្ងរ (ឧ. គម្រោងប្រភេទ ក)
- ប្រើប្រាស់អ្នកជំនាញពីខាងក្រៅ ឬគណៈកម្មាធិការផ្តល់ប្រឹក្សាក្នុងការតាមដានការអនុវត្តគម្រោងដែលមានភាពស្មុគស្មាញ និងងាយរងផលប៉ះពាល់ខ្លាំង (លើសពីគម្រោងប្រភេទ ក) និង
- ផ្ញើរបាយការណ៍តាមដានសាមយិកពីវិធានការការពារ ដូចបានព្រមព្រៀងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី។

64. នៅកម្រិតគម្រោង ធនាគារអភិវឌ្ឍន៍អាស៊ីនឹងវាយតម្លៃលទ្ធផលគម្រោង ធៀបជាមួយនឹងការប្តេជ្ញារបស់អ្នកខ្ចីដែលបានព្រមព្រៀងក្នុងកិច្ចព្រមព្រៀង។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងធ្វើសកម្មភាពតាមដានដូចខាងក្រោមដើម្បីត្រួតពិនិត្យការអនុវត្តគម្រោង ៖

- រៀបចំចុះត្រួតពិនិត្យដល់មូលដ្ឋានជាទៀងទាត់ សម្រាប់គម្រោងដែលមានផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន ឬសង្គម
- រៀបចំបេសកកម្មចុះត្រួតពិនិត្យដោយមានការវាយតម្លៃលម្អិតដោយមន្ត្រី ឬអ្នកឯកទេសគោលនយោបាយការពារ ឬទីប្រឹក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់គម្រោងដែលមានផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន ឬសង្គម (ឧ. គម្រោងប្រភេទ ក)

- វាយតម្លៃរបាយការណ៍តាមដានសាមយិក ដែលអ្នកខ្ចី/អតិថិជនផ្ញើមក ដើម្បីធានាថា ផលប៉ះពាល់ និងហានិភ័យអវិជ្ជមានត្រូវបានកាត់បន្ថយតាមការគ្រោងទុក និងតាមការព្រមព្រៀងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី
- ធ្វើការជាមួយអ្នកខ្ចី/អតិថិជនដើម្បីកែតម្រូវតាមលទ្ធភាពដែលអាចធ្វើទៅបាន នូវការមិនបំពេញតាមការសន្យាការពាររបស់អ្នកខ្ចី/អតិថិជននៅក្នុងកិច្ចព្រមព្រៀង និងធ្វើការដោះស្រាយបង្កើតឱ្យមានអនុលោមភាពឡើងវិញ និង
- រៀបចំរបាយការណ៍បញ្ចប់គម្រោងដែលវាយតម្លៃពីការសម្រេចបានកម្មវត្ថុ និងលទ្ធផលតាមការរំពឹងទុកនៃផែនការការពារ តាមរយៈការប្រៀបធៀបលក្ខខណ្ឌគោល និងលទ្ធផលនៃការតាមដាន។

65. នៅកម្រិតកម្មវិធី ធនាគារអភិវឌ្ឍន៍អាស៊ីនឹងតាមដានការអនុវត្តគោលនយោបាយការការពារក្នុងសាវតារបស់អនុគម្រោង ដោយផ្អែកតាមការវាយតម្លៃនៅកម្រិតគម្រោងដោយក្រុមគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ សេចក្តីសង្ខេបព័ត៌មានស្តីពីការអនុវត្តការងារ និងវឌ្ឍនភាពនៃការការពារ នឹងត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍អនុវត្តន៍ការងារប្រចាំឆ្នាំ (APR) ដែលធនាគារអភិវឌ្ឍន៍អាស៊ីដាក់ជូនមូលនិធិអាកាសធាតុបៃតង។

## ច.យន្តការដោះស្រាយបណ្តឹងតវ៉ា

66. ផ្អែកតាមសេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារអភិវឌ្ឍន៍អាស៊ីតម្រូវឱ្យអ្នកខ្ចី/អតិថិជនបង្កើត និងរក្សាយន្តការដោះស្រាយបណ្តឹងតវ៉ាមួយដើម្បីទទួល និងសម្របសម្រួលដោះស្រាយក្តីបារម្ភ និងបណ្តឹងរបស់ក្រុមមនុស្សរងផលប៉ះពាល់ ពីបញ្ហាសង្គម និងបរិស្ថានដែលកើតមានដោយសារគម្រោងរបស់អ្នកខ្ចី/អតិថិជន នៅកម្រិតគម្រោង។ យន្តការដោះស្រាយបណ្តឹងតវ៉ាត្រូវមានទំហំសមាមាត្រនឹងហានិភ័យ និងផលប៉ះពាល់របស់គម្រោង។ យន្តការនេះត្រូវតែអាចដោះស្រាយក្តីបារម្ភ និងបណ្តឹងតវ៉ារបស់ក្រុមមនុស្សរងផលប៉ះពាល់បានឆាប់រហ័ស ដោយប្រើប្រាស់នូវដំណើរការដែលងាយយល់ និងមានតម្លាភាព និងដែលមានការគិតគូរពីយេនឌ័រ មានលក្ខណៈសមស្របនឹងវប្បធម៌របស់ក្រុមមនុស្សរងផលប៉ះពាល់ និងអាចប្រើប្រាស់បានដោយក្រុមមនុស្សរងផលប៉ះពាល់គ្រប់ស្រទាប់វណ្ណៈ។ អ្នកខ្ចី/អតិថិជននឹងបានដឹងពីយន្តការដោះស្រាយបណ្តឹងតវ៉ាដោយឡែកមួយរបស់មូលនិធិអាកាសធាតុបៃតង សម្រាប់ជាមធ្យោបាយដោះស្រាយបណ្តឹងតវ៉ា ក្រៅពីលក្ខខណ្ឌតម្រូវរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

## ឆ.យន្តការគណនេយ្យភាព

67. ក្រុមមនុស្សរងផលប៉ះពាល់ពីគម្រោង ក៏អាចដាក់ពាក្យបណ្តឹងតាមរយៈយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ។ យន្តការគណនេយ្យភាពបង្កើតឱ្យមាននូវដំណើរការ និងវេទិកាឯករាជ្យមួយដែលក្រុមមនុស្សរងផលប៉ះពាល់អវិជ្ជមានពីគម្រោងផ្តល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី អាចប្តឹងតវ៉ាទាមទារដំណោះស្រាយចំពោះបញ្ហារបស់ពួកគេ និងរាយការណ៍ពីការរំលោភបំពានគោលនយោបាយប្រតិបត្តិ និងនីតិវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ យន្តការគណនេយ្យភាពចែកចេញជាដំណាក់កាលដាច់ដោយឡែក (តែពាក់ព័ន្ធគ្នា) ចំនួន ២ ៖ (១) ដំណាក់កាលពិគ្រោះយោបល់ ដែលដឹកនាំដោយអ្នកសម្របសម្រួលគម្រោងពិសេសរបស់ធនាគារ

អភិវឌ្ឍន៍អាស៊ី ដែលរាយការណ៍ប្រាប់ប្រធានធនាគារអភិវឌ្ឍន៍អាស៊ីដោយផ្ទាល់ ដើម្បីជួយក្រុមមនុស្សរងផលប៉ះពាល់ពីគម្រោងក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហារបស់ពួកគេ និង (២) ដំណាក់កាលវាយតម្លៃអនុលោមភាព ដែលដឹកនាំដោយគណៈកម្មការពិនិត្យអនុលោមភាពដែលមានសមាជិក ៣ រូប ហើយគណៈកម្មការនេះនឹងរាយការណ៍ប្រាប់ក្រុមប្រឹក្សាភិបាល។ គណៈកម្មការពិនិត្យអនុលោមភាព ស៊ើបអង្កេតរាល់ការប្តឹងពីការរំលោភបំពានគោលនយោបាយប្រតិបត្តិ និងនីតិវិធីដែលកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី រួមទាំងគោលនយោបាយការពារផង ដែលការរំលោភបំពាននោះបណ្តាលឱ្យ ឬអាចនឹងបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដោយផ្ទាល់ចំពោះក្រុមមនុស្សរងផលប៉ះពាល់ពីគម្រោង និងផ្តល់អនុសាសន៍ពីរបៀបធានានូវភាពអនុលោមតាមគោលនយោបាយ និងនីតិវិធីទាំងនោះ។

## ៩.ការរៀបចំការអនុវត្ត

68. ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមក្នុងកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន នឹងត្រូវបានអនុវត្តដោយធនាគារអភិវឌ្ឍន៍អាស៊ីក្នុងនាមជាស្ថាប័នដែលទទួលស្គាល់ដោយមូលនិធិអាកាសធាតុបៃតង និងជាស្ថាប័នប្រតិបត្តិ (EE) សម្រាប់កម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន។

69. នៅកម្រិតកម្មវិធី ធនាគារអភិវឌ្ឍន៍អាស៊ីនឹងតាមដានការអនុវត្ត និងការអនុវត្តការងារពាក់ព័ន្ធនឹងការការពារនៅកម្រិតសាវតា ដោយផ្អែកលើការតាមដានដោយក្រុមគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ តួនាទីនេះនឹងត្រូវបានដាក់បញ្ចូលក្នុងការទទួលខុសត្រូវផ្នែកមុខងាររបស់ក្រុម ដែលគ្រប់គ្រងកម្មវិធីស្តារសេដ្ឋកិច្ចបៃតងនៃកម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន ក្នុងផ្នែកទទួលបន្ទុកតំបន់អាស៊ីអាគ្នេយ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ក្នុងតួនាទីនេះ បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលគ្រប់គ្រងកម្មវិធីស្តារភាពបៃតងនៃ កម្មវិធីហិរញ្ញប្បទានបៃតងជម្រុញការស្តារសេដ្ឋកិច្ចអាស៊ាន នឹងសហការយ៉ាងស្និតរមួតជាមួយអ្នកឯកទេសផ្នែកបរិស្ថាន និងសង្គមដែលតាមដានសាវតាជារួមរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅអាស៊ីអាគ្នេយ៍។

70. នៅកម្រិតអនុគម្រោង រដ្ឋាភិបាលរបស់អ្នកខ្ចីនឹងធ្វើការវាយតម្លៃសង្គម និងបរិស្ថាន រៀបចំការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមមនុស្សរងផលប៉ះពាល់ និងសហគមន៍ រៀបចំ និងអនុវត្តផែនការការពារតាមដានការអនុវត្តផែនការទាំងនេះ និងរៀបចំ និងដាក់របាយការណ៍តាមដាន។

71. ធនាគារអភិវឌ្ឍន៍អាស៊ីនឹងពន្យល់ពីលក្ខខណ្ឌតម្រូវផ្នែកគោលនយោបាយដល់អ្នកខ្ចី/អតិថិជន ជួយឱ្យអ្នកខ្ចី/អតិថិជនបំពេញលក្ខខណ្ឌតម្រូវទាំងនោះក្នុងពេលដំណើរការ និងអនុវត្តគម្រោង តាមរយៈកម្មវិធីកសាងសមត្ថភាពជានាការអង្កេតលម្អិត និងការវាយតម្លៃ និងផ្តល់ការតាមដាន និងការត្រួតពិនិត្យ។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងតាមដានការអនុលោមតាមគោលនយោបាយការពារក្នុងពេលអនុវត្តគម្រោង។ របាយការណ៍បញ្ចប់គម្រោង និងរបាយការណ៍ស្តីពីការវាយតម្លៃការអនុវត្តការងារក្នុងគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងរួមបញ្ចូលការវាយតម្លៃ

ការអនុវត្តគោលនយោបាយការពារ។ អ្នកឯកទេសផ្នែកគោលនយោបាយការពារបរិស្ថាន និងសង្គមជាអ្នកអនុវត្ត ការទទួលខុសត្រូវរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដោយផ្អែកតាមបេសកកម្មថ្នាក់ប្រទេស និងផ្តោតលើវិស័យជាក់លាក់។

72. ក្រោមសមាសភាគទី ៣ ការកសាងសមត្ថភាពនឹងគាំទ្រដល់ការអនុវត្តគោលនយោបាយការពារប្រកបដោយប្រសិទ្ធភាពសម្រាប់គម្រោងជាក់លាក់ តាមរយៈការបណ្តុះបណ្តាលបុគ្គលិករបស់ស្ថាប័នគាំទ្រគម្រោង ដើម្បីកសាងការយល់ដឹងស្តីពីលក្ខខណ្ឌតម្រូវសម្រាប់ការពារ (បរិស្ថាន និងសង្គម) របស់ធនាគារអភិវឌ្ឍន៍អាស៊ី និង មូលនិធិអាកាសធាតុបៃតង ក៏ដូចជាពង្រឹងជំនាញ សមត្ថភាព និងចំណេះដឹងស្តីពីការតាមដាន និងការអនុវត្តផែនការគ្រប់គ្រងដែលពាក់ព័ន្ធនឹងបរិស្ថាន ការតាំងទីលំនៅជាថ្មី និងក្រុមជនជាតិដើមភាគតិច។

## ឧបសម្ព័ន្ធ ១ ៖ គំរូឯកសារ និងតារាងផ្ទៀងផ្ទាត់របស់ធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់ការចាត់ចំណាត់ថ្នាក់ ការអេក្រេតលម្អិត និងការតាមដាន

ធនាគារអភិវឌ្ឍន៍អាស៊ីប្រើប្រាស់តារាងផ្ទៀងផ្ទាត់សម្រាប់ការត្រួតពិនិត្យ និងចាត់ចំណាត់ថ្នាក់ហានិភ័យ ដែលមានបង្ហាញក្នុងតំណភ្ជាប់ឯកសារដែលពាក់ព័ន្ធនឹងក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមនេះ។ សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពាររួមបញ្ចូលប្លង់របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន ផែនការតាំងទីលំនៅជាថ្មី និងផែនការក្រុមជនជាតិដើមភាគតិចដែលត្រូវរៀបចំឡើងជាចាំបាច់សម្រាប់គម្រោងប្រភេទ ក។ សេចក្តីថ្លែងការណ៍នៃគោលនយោបាយការពារនឹងរួមបញ្ចូលផងដែរនូវប្លង់ក្របខណ្ឌវាយតម្លៃបរិស្ថាន និងក្របខណ្ឌវាយតម្លៃ ក្របខណ្ឌស្តីពីការតាំងទីលំនៅជាថ្មី និងក្របខណ្ឌរៀបចំផែនការក្រុមជនជាតិដើមភាគតិចដែលត្រូវរៀបចំឡើងជាចាំបាច់សម្រាប់គម្រោងប្រភេទអន្តរការីហិរញ្ញវត្ថុ។

| | |
|---|---|
| តារាងសកម្មភាពវិនិយោគដែលត្រូវបានហាមឃាត់របស់ធនាគារអភិវឌ្ឍន៍អាស៊ី | សូមមើល តំណភ្ជាប់ឯកសារទី ១ (ADB SPS 2009) សេចក្តីបន្ថែម ៥ |
| ប្លង់របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន | សូមមើល តំណភ្ជាប់ឯកសារទី១ (ADB SPS 2009) សេចក្តីបន្ថែម ១ ឧបសម្ព័ន្ធ |
| ប្លង់ផែនការតាំងទីលំនៅជាថ្មី | សូមមើល តំណភ្ជាប់ឯកសារទី ១ (ADB SPS 2009) សេចក្តីបន្ថែម ២ ឧបសម្ព័ន្ធ |
| ប្លង់ផែនការក្រុមជនជាតិដើមភាគតិច | សូមមើល តំណភ្ជាប់ឯកសារទី ១ (ADB SPS 2009) សេចក្តីបន្ថែម ៣ ឧបសម្ព័ន្ធ |
| ប្លង់ការវាយតម្លៃបរិស្ថាន និងក្របខណ្ឌវាយតម្លៃ | សូមមើល តំណភ្ជាប់ឯកសារទី ១ (ADB SPS 2009) សេចក្តីបន្ថែម ៤ ឧបសម្ព័ន្ធ ១ |
| ប្លង់ក្របខណ្ឌស្តីពីការតាំងទីលំនៅជាថ្មី | សូមមើល តំណភ្ជាប់ឯកសារទី ១ (ADB SPS 2009) សេចក្តីបន្ថែម ៤ ឧបសម្ព័ន្ធ ២ |
| ប្លង់ក្របខណ្ឌរៀបចំផែនការក្រុមជនជាតិដើមភាគតិច | សូមមើល តំណភ្ជាប់ឯកសារទី ១ (ADB SPS 2009 ) សេចក្តីបន្ថែម ៤ ឧបសម្ព័ន្ធ ៣ |
| តារាងផ្ទៀងផ្ទាត់ការវាយតម្លៃបរិស្ថានរហ័ស | សូមមើល តំណភ្ជាប់ឯកសារទី ២ ផ្នែកទី ១ |
| ទម្រង់នៃការចាត់ចំណាត់ថ្នាក់ ៖ បរិស្ថាន | សូមមើល តំណភ្ជាប់ឯកសារទី ២ ផ្នែកទី ២ |

| | |
|---|---|
| ទម្រង់នៃការចាត់ចំណាត់ថ្នាក់ ៖ ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត | សូមមើល តំណភ្ជាប់ឯកសារទី ២ ផ្នែកទី ២ |
| ទម្រង់នៃការចាត់ចំណាត់ថ្នាក់ ៖ ក្រុមជនជាតិដើមភាគតិច | សូមមើល តំណភ្ជាប់ឯកសារទី ២ ផ្នែកទី ២ |
| គំរូឯកសារទូទៅរបស់ធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់របាយការណ៍តាមដាន | សូមមើល តំណភ្ជាប់ឯកសារទី ២ ផ្នែកទី ៣ |
| គំរូឯកសាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់របាយការណ៍តាមដានសង្គម | សូមមើល តំណភ្ជាប់ឯកសារទី ២ ផ្នែកទី ៣ |